គណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្ម
# ប្រចាំត្រីមាសទី២ ឆ្នាំ២០១៦
# នៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី៣
# របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

(សេចក្តីព្រាង)

អគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ខែកញ្ញា ឆ្នាំ២០១៦

# មាតិកានុក្រម


សេចក្ដីសង្ខេប........................................................................................ ០១

១.សេចក្ដីផ្ដើម........................................................................................ ០៣

២.លទ្ធផលសម្រេចបានប្រចាំត្រីមាសទី២ ............................................................ ០៦

៣.វឌ្ឍនភាពតាមផ្នែក.................................................................................. ១៤

៤.បញ្ហាប្រឈម .......................................................................................... ៣៥

៥.សំណូមពរ ............................................................................................ ៣៦

៦.សន្និដ្ឋាន ............................................................................................. ៣៧

ឧបសម្ព័ន្ធ.............................................................................................. ៣៩

## សេចក្ដីសង្ខេប

ការរៀបចំរបាយការណ៍នេះ គឺមានគោលដៅនិងគោលបំណងក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ របស់អង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្ដោតយកតែត្រីមាសទី២ ប៉ុណ្ណោះ។ ទន្ទឹមនេះ ការវាយតម្លៃ និងរៀបចំឱ្យមានជារបាយការណ៍នេះ ក៏នឹងផ្ដល់លទ្ធភាពក្នុងការបង្ហាញវឌ្ឍនភាពការងារ កំណត់នូវបញ្ហាប្រឈមនានាដែលទាមទារឱ្យមានកែលម្អ និងកំណត់នូវការងារជាអាទិភាពដែលត្រូវបន្តអនុវត្តសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅកម្រិតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល។ ជាក់ស្ដែង បម្រែបម្រួលលទ្ធផលនៃការវាយតម្លៃត្រីមាសទី២ នឹងអាចយកមកធៀបនឹងលទ្ធផលនៃការវាយតម្លៃ ត្រីមាសទី១ ឆ្នាំ២០១៦ ដែលត្រូវបានរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដោយបង្ហាញឱ្យឃើញនូវវឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅការងារជំហានបន្ទាប់ និងទាមទារឱ្យមានការយកចិត្តដាក់ខ្ពស់បន្ថែមទៀតផងដែរ តាមរយៈការចូលរួមអនុវត្តដោយផ្ទាល់ពីអង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ។ ជាមួយគ្នានេះ ភាពខ្វះចន្លោះនៅក្នុងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ត្រូវបានកំណត់ផ្អែកលើរបាយការណ៍ដែលរៀបចំឡើងដោយអង្គភាពសាមី យោងលើផែនការសកម្មភាពដំណាក់កាលទី៣ (GDAP3) ដែលចាំបាច់ត្រូវការបន្តត្រួតពិនិត្យ កែលម្អ និងការពង្រឹងបន្ថែម ដោយ **អ.គ.ហ** និងពីគ្រប់អង្គភាពក្រោមឱវាទ កសហវ។ លើសពីនេះទៀត លទ្ធផលនៃការវាយតម្លៃត្រីមាសទី២នេះ នឹងផ្ដល់នូវមូលដ្ឋានយ៉ាងសំខាន់សម្រាប់ **អ.គ.ហ** រៀបចំយុទ្ធសាស្ត្រក្នុងការអនុវត្តផែនការសកម្មភាពរួមដែលបានដាក់ចេញ ដើម្បីសម្រេចគោលដៅក្នុងទស្សនវិស័យវែងឆ្ងាយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងន័យនេះ ភាពជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ គឺនឹងជួយគាំទ្រដល់ការសម្រេចបានផងដែរនូវប្រព័ន្ធថវិកាថ្មីដោយផ្ដោតជាសំខាន់លើគោលការណ៍ ០៤ គឺ (១) វិន័យថវិកា÷ ការប្រមូលផ្ដុំនៃឯកសារថវិកា និងលទ្ធភាពនៃការវិភាជថវិកាទៅតាមផែនការ (ពោលគឺការរៀបចំ និងការអនុវត្តចំណូលចំណាយ), (២) យុទ្ធសាស្ត្រវិភាជន៍ធនធាន÷ បង្ហាញពីលទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការផ្ដល់នូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដល់អង្គភាពផ្ដល់សេវាសាធារណៈ និងប្រើប្រាស់ធនធានហិរញ្ញវត្ថុដែលប្រមូលបានពីសាធារណជន និងសហគ្រាសនានា ដែលអាចឆ្លើយតបទាំងក្នុងគោលបំណងគោលនយោបាយ និងគោលដៅ, (៣) ប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ÷ ផ្ដោតលើធនធានហិរញ្ញវត្ថុដែលអាចបង្កើតជាតម្លៃក្នុងការប្រើប្រាស់ដើម្បីផ្ដល់សេវាសាធារណៈ និងការកាត់បន្ថយនូវការខាតបង់ប្រយោជន៍ផ្សេងៗ ហើយហើយការបង្កើនប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈជាការងារចាំបាច់ ដែលអាចធ្វើទៅបានតាមរយៈការកៀរគរចំណូល និងទាមទារនូវគណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសាធារណៈគ្រប់កម្រិត, និង (៤) ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានថវិកា÷ របាការណ៍ការអនុវត្តចំណូល-ចំណាយ។

ដោយឡែក យោងតាមរបាយការណ៍វាយនេះ យើងអាចសន្និដ្ឋាននូវផ្នែកទាំង ០៥ ជាសង្ខេបបានថា÷

**១. បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា សម្រេចបាន ៨០%÷** ផ្អែកលើសូចនាករសមិទ្ធកម្មគន្លឹះទាំង ៥ ឃើញថាគម្លាត ចំណូល និងចំណាយថវិកាជាតិកាន់តែតូចធៀបនឹងច្បាប់ថវិកា ដែលបានអនុម័ត, លំហូរចំណូល និងចំណាយថវិកាកាន់តែរលូន, ការទូទាត់សាច់ប្រាក់កាន់តែមានភាពល្អប្រសើរ ព្រមទាំងកាត់បន្ថយបានទាំងស្រុងនូវបញ្ហាបំណុលកកស្ទះ។ ទន្ទឹមនេះ ក៏ទាមទារឱ្យមានការពង្រឹងបន្ថែម ជាពិសេសលើប្រព័ន្ធ និង

ក្របខណ្ឌគតិយុត្តផ្សេងៗដែលជាមូលដ្ឋានក្នុងការគាំទ្រការងារនេះ។ ភាពជឿទុកចិត្តបាននៃថវិកានៅតែអាចធានាបាន ប៉ុន្តែនៅមិនទាន់មានស្ថិរភាពនៅឡើយ។

**២. បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ សម្រេចបាន ៨២%÷** ផ្អែកតាមលទ្ធផលចង្កោមសកម្មភាព យើងអាចសន្និដ្ឋានបានថា កិច្ចការសំខាន់ៗ និងចាំបាច់មួយចំនួន ជាពិសេស សមាសធាតុចាំបាច់អាចយកមកប្រើប្រាស់បាន សម្រាប់ធានាដល់ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បានទាន់ពេលវេលាតាមកាលកំណត់។ ផ្នែកនេះ នៅតែធានាបាន ប៉ុន្តែអាចនឹងជួបប្រទះកិច្ចប្រឈមនាពេលខាងមុខ ប្រសិនការបញ្ចប់ការងារ FMIS ដំណាក់កាលទី១ មិនទាន់ពេលវេលា និងកង្វះការចូលរួមរៀបចំ និងឆន្ទៈសម្រាប់ផែនការដំណាក់កាលទី២។

**៣. ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ សម្រេចបាន ៨៧%÷** ផ្អែកតាមលទ្ធផលចង្កោមសកម្មភាព ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ គឺជាដំណាក់កាលដ៏សំខាន់នឹងចាំបាច់ដែលមិនអាចមើលរំលងបាននូវរាល់ការរៀបចំសកម្មភាពលម្អិតគាំទ្រពីគ្រប់អង្គភាព កសហវ និងក្រសួងស្ថាប័ន។ ផ្នែកនេះកាន់តែសំខាន់ ដែលការងារចាំបាច់ត្រូវពន្លឿនការរៀបចំ និងអនុវត្ត ដូចជា ការរៀបចំផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៧-២០២៥, ការរៀបចំ MTEF និងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុនៅថ្នាក់ក្រោម ជាតិ។

**៤. ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ សម្រេចបាន ៧៦ %÷** ផ្អែកតាមលទ្ធផលចង្កោមសកម្មភាព ផ្នែកនេះសម្រេចបានទាប នោះបញ្ជាក់អំពីភាពចាំបាច់ក្នុងការបន្ត និងពង្រឹងការគាំទ្រដល់ផ្នែកនេះ បន្ថែមទៀតនោះ គឺ ក្របខ័ណ្ឌថវិកា ក្របខ័ណ្ឌគណនេយ្យភាព និងក្របខណ្ឌ សវនកម្មដោយផ្អែកលើសមិទ្ធកម្មដែលផ្សារភ្ជាប់ការចំណាយសម្រាប់កម្មវិធីនីមួយ។ ផ្នែកនេះ មានសកម្មភាពលម្អិតគាំមិនទាន់ពេញលេញ ដែលចាំបាច់ឱ្យមានការរៀបចំ និងកំណត់ការទទួលខុសត្រូវច្បាស់លាស់។

**៥. ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាពសម្រេចបាន ៧២%÷** ផ្អែកតាមលទ្ធផលចង្កោមសកម្មភាព ផ្នែកនេះសម្រេចបានទាបជាង បណ្តាផ្នែកទាំង ៤ផ្សេងទៀត នោះបញ្ជាក់អំពីភាពចាំបាច់ក្នុងការបន្ត និងពង្រឹងការគាំទ្រដល់ផ្នែកនេះ បន្ថែមទៀតនោះ គឺ ពង្រឹងនិងពង្រីកភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រងសមត្ថភាពបច្ចេកទេស ភាពជាម្ចាស់ ការទទួលខុសត្រូវ និងមានសមានគតិភាពជាមួយនឹង ការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ និងដំណាក់កាលបន្ទាប់។ អគ្គនាយកដ្ឋានមួយចំនួនមិនបានរៀបចំសកម្មភាពគាំទ្រផ្នែកនេះ និងទាមទារឱ្យមានការសហការជាមួយកំណែទម្រង់រដ្ឋបាលសាធារណៈ៕

## ១. សេចក្តីផ្តើម

### ១.១. សាវតាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្នុងស្មារតីនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រកាសដាក់ឱ្យអនុវត្ត នៅខែធ្នូ ឆ្នាំ២០០៤ សម្រាប់រយៈពេលវែង ក្នុងគោលដៅប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ស្របតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ ដែលមានលក្ខណៈ វិមជ្ឈការ ផ្តោតលើធាតុចេញ និងសមិទ្ធកម្មនៅឆ្នាំ២០២៥។ ជាក់ស្តែង ក្នុងឋានៈជាសសរស្តម្ភមួយនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) មានភារកិច្ចដឹកនាំ, រៀបចំ, អនុវត្ត, សម្របសម្រួល និង វាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយកំណត់យកជា ៤ ជំហាន និងដំណាក់កាល ដូចខាងក្រោម÷

- ដំណាក់កាលទី១ : “ភាពជឿទុកចិត្តបាននៃថវិកា” ត្រូវបានអនុវត្ត ចាប់ពីឆ្នាំ២០០៤ ដល់ ឆ្នាំ២០០៨,
- ដំណាក់កាលទី២ : “គណនេយ្យភាពហិរញ្ញវត្ថុ” សម្រាប់ឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៥,
- ដំណាក់កាលទី៣ : “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០ និង
- ដំណាក់កាលទី៤ : “គណនេយ្យភាពចំពោះសមិទ្ធកម្ម” ពីឆ្នាំ២០២១ ដល់ ឆ្នាំ២០២៥។

ជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា ពឹងផ្អែកជាសំខាន់លើការប្រមូលផ្តុំនូវរាល់កិច្ចខិតខំប្រឹងប្រែងនិងកិច្ចសហការជិតស្និទ្ធពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុង/រវាងអគ្គនាយកដ្ឋាន និងអង្គភាពក្រោម ឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាក្រសួង-ស្ថាប័ន ពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា។ ចលនាការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តម្រូវឱ្យមានការគាំទ្រប្រកបដោយឆន្ទៈ, ការប្តេជ្ញាចិត្តខ្ពស់, ភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ពីថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់, ចាប់ពីកម្រិតបច្ចេកទេសរហូតដល់កម្រិតគោលនយោបាយ ស្របពេលដំណើរការនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្លងកាត់ពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ មិនអាចគេចផុតពីការពើបប្រទះនឹងបញ្ហាប្រឈមដ៏ស្រួចស្រាលមួយចំនួននោះទេ ដែលប្រការនេះចាំបាច់ត្រូវមានដំណោះស្រាយសមានគតិនិងទាន់ពេល។ ដើម្បីសម្រេចចក្ខុវិស័យរយៈពេលខ្លី មធ្យម និងវែងឆ្ងាយ **គ.ហ.ស.** បានផ្តួចផ្តើមនិងបង្កើតឱ្យមានយន្តការការងារប្រទាក់ក្រឡាគ្នាចំនួនបី គឺ÷

- ទី១. យន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និង
- ទី២. យន្តការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រោមការសម្របសម្រួលរបស់ **អ.គ.ហ.**
- ទី៣.វិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យនិងតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ដោយឡែក ឆ្នាំ២០១៦ គឺជាឆ្នាំចាប់ផ្តើមអនុវត្តដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បន្ទាប់ពី ដំណាក់កាលទី២ បានសម្រេចជោគជ័យក្នុងការពង្រឹងបាននូវគណនេយ្យភាពហិរញ្ញវត្ថុ តាមរយៈការពង្រឹងនិងកំពុងបន្តពង្រឹងថែមទៀត ក្នុងការដាក់ឱ្យអនុវត្តនូវសមាសភាគសំខាន់ៗជាមូលដ្ឋាននានា ជាអាទិ៍ ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី, ប្លង់គណនេយ្យថ្មី, អង្គភាពថវិកា, ថវិកាកម្មវិធីពេញលេញនៅក្រសួងទាំង២៥ និងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី១ ដែលបានបញ្ចប់នៅដំណាច់ឆ្នាំ២០១៦។

ក្នុងដំណាក់កាលទី៣ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្តោតលើចំណុចអាទិភាពចំនួន ៣គឺ

១. ការគ្រប់គ្រងការប្រមូលចំណូល

២. ការពង្រឹង និងពង្រីកការរៀបចំប្រព័ន្ធ FMIS

៣. ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី

### ១.២. គោលបំណង

របាយការណ៍ការនេះពិតណាស់ គឺនឹងបង្ហាញពីវឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅការងារបន្ត ទាំងសម្រាប់អគ្គលេខាធិការដ្ឋាន **អ.គ.ហ.** ដែលជាសេនាធិការឱ្យ **គ.ហ.ស** ក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួល លើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទាំងអង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ និងក្រសួង ស្ថាប័នផងដែរ ក្នុងការបន្តគិតគូរ និងគូសរៀសស្វែងរកដំណោះស្រាយ និងបង្កើតក្របខណ្ឌ យន្តការ យុទ្ធសាស្ត្រ និងនីតិវិធីការងារថ្មីក្នុងគោលដៅគាំទ្រ ពង្រឹង និងពង្រីកការអនុវត្តការងារកែទម្រង់ទាំងសម្រាប់ក្របខ័ណ្ឌស្ថាប័ន និងរាជរដ្ឋាភិបាល ឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។ ជាចុងក្រោយ របាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃនេះ នឹងត្រូវចាត់ជាឧបករណ៍ និងជាតម្លៃបន្ថែមសម្រាប់ទ្រទ្រង់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលបន្ទាប់ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព និងទុកជាមូលដ្ឋានព័ត៌មានគ្រប់ជ្រុងជ្រោយដើម្បីបន្តចង្អុលនិងបំភ្លឺកិច្ចដំណើរការនៃការអនុវត្តការងារកែទម្រង់ និងដើម្បីជាប្រយោជន៍ដល់គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ១.៣. វិធីសាស្ត្រការរៀបចំរបាយការណ៍

ដើម្បីធានាបាននូវការអភិវឌ្ឍគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃការរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ផ្តើមពីត្រីមាស រហូតដល់ ប្រចាំឆ្នាំ និងពីដំណាក់កាលទី១ ទៅដំណាក់កាលបន្ទាប់ ក្រុមការងាររបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ**) ដែលមានការចូលរួមពីអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នរដ្ឋដែលពាក់ព័ន្ធ តាមរយៈការអនុវត្តផ្ទាល់ និងរៀបចំចេញជារបាយការណ៍ និងផ្ញើមក **អ.គ.ហ.** ដើម្បីពិនិត្យវាយតម្លៃ និងបូកសរុបចេញជារបាយការណ៍រួម។ កិច្ចដំណើរការរៀបចំរបាយការណ៍នេះ គឺតាមរយៈផ្នែកទាំង៥ នៃ **អ.គ.ហ.** ដែលទទួលបន្ទុកអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមមាន÷

១. **ផ្នែកគោលនយោបាយ**÷ អគ្គនាយកនាយកដ្ឋានគោលនយោយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ។

២. **ផ្នែកចំណូល**÷ អគ្គនាយកដ្ឋានពន្ធដារ, គយនិងរដ្ឋាករកម្ពុជា, ទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, និងឧស្សាហកម្មហិរញ្ញវត្ថុ។

៣. **ផ្នែករៀបចំថវិកា**÷ អគ្គនាយកដ្ឋានថវិកា និង រដ្ឋបាលហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ។

៤. **ផ្នែកអនុវត្តថវិកា**÷ អគ្គនាយកដ្ឋានរតនាគារជាតិ និង លទ្ធកម្មសាធារណៈ។

៥. **ផ្នែកគាំទ្រទូទៅនិងកសាងសមត្ថភាព**÷ អគ្គលេខាធិការដ្ឋាន កសហវ, សវនកម្មផ្ទៃក្នុង, អគ្គាធិការដ្ឋាន, ក្រុមការងារ FMIS និង វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកនីមួយៗ ត្រូវចាំបាច់ប្រមូលរបាយការណ៍ពីគ្រប់អង្គភាពទទួលបន្ទុកទាំងត្រីមាស និងឆ្នាំ ផ្អែកលើផែនការសកម្មភាពរួបដំណាក់កាលទី៣ (GDAP3) ដើម្បីពិនិត្យ និងរៀបចំបូកសរុប ដោយបង្ហាញនូវវឌ្ឍនភាព បញ្ហាប្រឈម

និងសំណើសំណូមពរ ហើយឆ្លងផែនការនេះរួមគ្នានៅក្នុង **អ.គ.ហ.** ទាំងមូល មុននឹងដាក់បញ្ចូលជារបៀបវារៈសម្រាប់កិច្ចប្រជុំពិភាក្សាជាមួយគ្រប់អង្គភាពក្រោមឱវាទ កសហវ និងក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសុំការពិនិត្យ និងសម្រេចបន្ថែម ក្នុងគោលដៅកែលម្អចំណុចដែលនៅខ្វះចន្លោះ។

## ១.៤. ទំហំ និងដែនកំណត់

ការរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃនេះ មានវិសាលភាពគ្របដណ្តប់តែអង្គភាពទាំង១២ ក្រោមឱវាទ កសហវ ស្របពេលដែលទម្រង់របាយការណ៍សរសេរនេះត្រូវបានធ្វើកែសម្រួល និងធ្វើបច្ចុប្បន្នភាព ក្នុងគោលដៅពង្រឹងសមានគតិភាព និងសង្គតិភាពជាមួយនឹងការវិវឌ្ឍនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពីមួយដំណាក់កាលទៅមួយដំណាក់កាល ជាពិសេស គឺផ្អែកលើផែនការសកម្មរួមដំណាក់កាលទី៣ (MAP3), និងផែនការសកម្មភាពរួមដំណាក់កាលទី៣ របស់អគ្គនាយកដ្ឋាន (GDAP3) ហើយគិតត្រឹមផែនការសកម្មភាព និងសូចនាករត្រីមាសទី២ ឆ្នាំ ២០១៦ តែប៉ុណ្ណោះ។

ជាមួយគ្នានេះ ការតាមដានត្រួតពិនិត្យសិមិទ្ធកម្ម ដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ**) ត្រូវបានធ្វើឡើងប្រកបដោយភាពម៉ត់ចត់ ច្បាស់លាស់ និងទៀងទាត់តាមរយៈកិច្ចប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំ នៃគណៈកម្មការដឹកនាំការងារកែទម្រង់សម្រាប់ធ្វើការវាយតម្លៃពីប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។

របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ នឹងរៀបរាប់ពីលទ្ធផលសម្រេចបាន ដោយលម្អិតទៅតាមផ្នែកនីមួយៗ រហូតដល់កម្រិតគោលបំណង និងចង្កោមសកម្មភាពធៀបនឹងសូចនាករ ព្រមទាំងលើកឡើងពីបញ្ហាប្រឈម សំណូមពរ និងការងារត្រូវធ្វើបន្តផងដែរ។

វិធីសាស្ត្រដែលប្រើប្រាស់សម្រាប់វាយតម្លៃសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាព ក្នុងត្រីមាសទី២ ឆ្នាំ២០១៦ នេះ ផ្អែកលើមូលដ្ឋាន ២ គឺ÷

១. សកម្មភាពការងារសម្រេចបានធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត

២. លទ្ធផលសម្រេចបានធៀបនឹងសូចនាករគោលដៅ។

ក្នុងនោះដែរ ការផ្តល់និទ្ទេសវាយតម្លៃលើវឌ្ឍនភាពសម្រេចបាន ត្រូវបានបែងចែកជា ៣ កម្រិត សម្រាប់គោលបំណង និងចង្កោមសកម្មភាពគឺ÷ ល្អ (៩០%-១០០%), មធ្យម (៨០%-៩០%), និង ខ្សោយ (ក្រោម ៨០%)។

## ២. លទ្ធផលសម្រេចបានប្រចាំត្រីមាសទី២

### ២.១. វឌ្ឍនភាពការអនុវត្តក្របខណ្ឌសូចនាករសមិទ្ធកម្មសហភាពអ៊ឺរ៉ុប

- កិច្ចព្រមព្រៀងហិរញ្ញវត្ថុជាមួយសហភាពអឺរ៉ុប គឺធ្វើការត្រួតពិនិត្យលើវឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ លើសូចនាករសមិទ្ធកម្មចំនួន ៨ ប្រចាំឆ្នាំ២០១៦។
- វឌ្ឍនភាពប្រចាំឆមាស ធៀបនឹងសូចនាករគោលដៅប្រចាំឆ្នាំ ដោយសារតែមិនទាន់បានរៀបចំបែងចែកសូចនាករគោលដៅប្រចាំត្រីមាស ឬ ឆមាសនៅឡើយ។ ចំពោះសូចនាករដែលមិនសម្រេចបានតាមគោលដៅ គឺជាកម្មវត្ថុនៃការកាត់បន្ថយថវិកាទ្រទ្រង់ (Budget Support)។
- វឌ្ឍនភាពតាមសូចនាករនីមួយៗ ត្រូវបានកំណត់នូវកម្រិតហានិភ័យ ដូចខាងក្រោម÷
  - កម្រិតទាប (៨០% ទៅ ៩៩%) កំណត់ដោយពណ៌បៃតង
  - កម្រិតមធ្យម (៥០% ទៅ ៧៩%) កំណត់ដោយពណ៌លឿង
  - កម្រិតខ្ពស់ (០% ទៅ ៤៩%) កំណត់ដោយពណ៌ក្រហម

## វឌ្ឍនភាពការអនុវត្តក្របខណ្ឌសូចនាករសមិទ្ធកម្មសហភាពអឺរ៉ុប

| ល.រ | លក្ខ័ណ្ឌជាក់លាក់ (សកម្មភាព) | អង្គភាពទទួលបន្ទុក | សូចនាករ ឆ្នាំ២០១៦ | វឌ្ឍនភាព | កម្រិតហានិភ័យ |
|---|---|---|---|---|---|
| ១ | កែលម្អគុណភាពស្ថិតិជាតិ | ក្រសួងផែនការ | ស្ថិតិគណនេយ្យជាតិឆ្នាំ ២០១៥ ត្រូវបានផ្សព្វផ្សាយ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ | បានបញ្ចប់ជាផ្លូវការគណនេយ្យជាតិ និងរបាយការណ៍សម្រាប់ឆ្នាំ២០១៥ ដែលគ្រោងផ្សព្វផ្សាយក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ (ប៉ាន់. ៩០%)។ | |
| ២ | កែលម្អប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | FMWG | ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តនៅ កសហវ និង រតនាគាររាជធានី ខេត្ត | បានដាក់ឱ្យដំណើរការពេញលេញ (៦ អគ្គនាយកដ្ឋាន និង ២៥ រតនាគាររាជធានី ខេត្ត) (១០០%)។ | គ្មាន |
| | | | បញ្ចប់ការរៀបចំគម្រោង FMIS ជំហានទី២ | បានរៀបចំសេចក្តីព្រាង ដែលសម្រេចបានប្រមាណ ៦៥%។ | |
| ៣ | ពង្រឹងសុក្រឹតភាព និងតម្លាភាពថវិកានៃការផ្ទេរថវិកាទៅថ្នាក់ក្រោមជាតិ | GDSNAF | ការផ្ទេរហិរញ្ញវត្ថុដោយភ្ជាប់លក្ខខណ្ឌទៅក្រុង ស្រុក នៃការអនុវត្តមុខងារសម្រាប់វិស័យបរិស្ថាន, អប់រំ, សុខាភិបាល និង អភិវឌ្ឍន៍ជនបទ | បានរៀបចំសេចក្តីព្រាងអនុក្រឹត្យការផ្ទេរហិរញ្ញវត្ថុទៅថ្នាក់ក្រោមជាតិ ស្តីពីការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ។ សម្រាប់ការអនុវត្តសូចនាករនេះ សម្រេចបាន ៧៥%។ | |
| ៤ | ពង្រឹងតម្លាភាពថវិកា | GDEPFP | TOFE និង GFS ប្រចាំខែ ត្រូវផ្សព្វផ្សាយមិនយូរជាង ៣ខែ ក្រោយពេលរបាយការណ៍ត្រូវបានបញ្ចប់ | បានផ្សព្វផ្សាយ TOFE និង GFS ទៀងទាត់តាមសូចនាករកំណត់ | |
| | | NAA | ផ្សព្វផ្សាយរបាយការណ៍សវនកម្មប្រចាំឆ្នាំស្តីពីការអនុវត្តហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានផ្សព្វផ្សាយមិនយឺតជាង៣ខែ ក្រោយរបាយការណ៍សវនកម្មអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា | បានផ្សព្វផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៦-២០១៤ ប៉ុន្តែសហភាពអឺរ៉ុប គឺចង់ឱ្យផ្សព្វផ្សាយរបាយការណ៍សវនកម្មលើច្បាប់ទូទាត់។ | |

| | | | | | |
|---|---|---|---|---|---|
| ៥ | បង្កើនការអនុវត្តថវិកាផ្អែកលើសមិទ្ធកម្ម | GDB | បង្កើតយន្តការត្រួតពិនិត្យសម្រាប់ការសាកល្បង ការអនុវត្តថវិកាផ្អែកលើសមិទ្ធកម្ម | គ្មានវឌ្ឍនភាព | 🔴 |
| ៦ | ពង្រឹងប្រសិទ្ធភាព និងមុខងារសវនកម្ម | GDIA | គោលការណ៍ស្ដីពីសវនកម្មផ្ទៃក្នុងត្រូវបានអនុម័ត | គោលការណ៍ស្ដីពីសវនកម្មផ្ទៃក្នុងត្រូវត្រួតពិនិត្យ និង កែតម្រូវ (៦០%) | 🟡 |
| | | | អង្គភាពសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតយ៉ាងហោចណាស់ ៨០%នៃក្រសួង ស្ថាប័ន ដែលគ្រប់ដណ្ដប់យ៉ាងហោចណាស់ ៥០% នៃចំណាយចរន្ត រួមបញ្ចូល ក្រសួងអប់រំ យុវជន និងកីឡា | ក្រសួងចំនួន ២៨ បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង លើកលែងតែក្រសួងព្រះបរមរាជវាំង, សហគ្រាសសាធារណៈ និងស្ថាប័ន (តុលាការកំពូល, សាលាឧទ្ធរណ៍...) | 🟢 |
| ៧ | ពង្រឹងការប្រមូលចំណូល | GDEPFP And Revenue Agencies | ចំណូលចរន្តប្រចាំឆ្នាំកើនឡើង ០,៥ ពិន្ទុភាគរយ នៃ ផ.ស.ស | សម្រេចបាន ៥២,៥% ធៀបនឹងគោលដៅ *(ផ្អែកលើការគណនារបស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ)* | 🟡 |
| ៨ | បង្កើនតម្លាភាពលទ្ធកម្មសាធារណៈ | GDPP | ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន រួមទាំងឱកាសលទ្ធកម្ម (Procurement Opportunity) និងការប្រគល់កិច្ចសន្យាត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | (១) ផែនការលទ្ធកម្មរបស់អង្គភាពលទ្ធកម្ម (ក្រសួង ស្ថា-ប័ន, មន្ទីរជំនាញ និងសហគ្រាសសាធារណៈ និង ឱកាសនៃលទ្ធកម្ម (សេចក្ដីជូនដំណឹងចូលរួមដេញថ្លៃ) និងសេចក្ដីជូនដំណឹងការប្រគល់កិច្ចសន្យា ត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់ GDPP (លើសពិដានកំណត់, Threshold)។<br>(២) សម្រាប់ក្រោមពិដានកំណត់ការផ្សព្វផ្សាយនៅមានកម្រិតនៅឡើយ។<br>**សរុបសម្រេចបាន ៩០%** | 🟢 |

***កម្រិតហានិភ័យ*** ÷ 🔴 ខ្ពស់ (ទាបជាង ៥០%) 🟡 មធ្យម (៥០%-៨៩%) 🟢 ទាប (៩០%-៩៩%)

## ២.២. តារាងសង្ខេបសូចនាករសមិទ្ធកម្មគន្លឹះប្រចាំត្រីមាសទី២

| សូចនាករ | គោលដៅ | វឌ្ឍនភាពត្រីមាសទី២ ឆ្នាំ២០១៥ | វឌ្ឍនភាពត្រីមាសទី២ ឆ្នាំ២០១៦ |
|---|---|---|---|
| **១. លទ្ធផលចំណូលក្នុងស្រុកសរុបជាបណ្តើរៗកាន់តែខិតទៅរកគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ** | ចំណូលក្នុងស្រុកសរុបសម្រេចបាន+/-៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់ | ចំណូលក្នុងស្រុកសម្រេចបាន÷<br>□ត្រីមាសទី១: ២៣,១%<br>• ចំណូលចរន្ត : ២៣, ៩%<br>• ចំណូលមូលធន (ក្នុងស្រុក) : ៧, ៣%<br>□ត្រីមាសទី២: ២៨, ៩%<br>• ចំណូលចរន្ត : ២៩, ៧%<br>• ចំណូលមូលធន (ក្នុងស្រុក): ៩, ២%<br>សម្រាប់ការអនុវត្តផែនការប្រមូលចំណូលសារពើពន្ធធៀបនឹងផែនការប្រចាំត្រីមាសទី២ ÷<br>□គយនិងរដ្ឋាករ÷ ១១៦, ៥៤%<br>□ពន្ធដារ÷ ១០៧, ០៣%<br>សម្រាប់ការអនុវត្តផែនការប្រមូលចំណូលមិនមែនសារពើពន្ធធៀបនឹងផែនការ÷<br>□ទ្រព្យសម្បត្តិរដ្ឋ÷ ៧៣, ៧៧%<br>ឧស្សាហកម្មហិរញ្ញវត្ថុ ÷២៨៩, ៥៥% | ចំណូលក្នុងស្រុកសម្រេចបាន÷<br>□ត្រីមាសទី១: ២៧, ២%<br>• ចំណូលចរន្ត : ២៥, ២%<br>• ចំណូលមូលធន (ក្នុងស្រុក) : ៥. ៥%<br>□ត្រីមាសទី២: ២៨, ២%<br>• ចំណូលចរន្ត : ២៨, ៦%<br>• ចំណូលមូលធន (ក្នុងស្រុក) ៤, ០%<br>សម្រាប់ការអនុវត្តផែនការប្រមូលចំណូលសារពើពន្ធធៀបនឹងផែនការប្រចាំត្រីមាសទី២ ÷<br>□គយនិងរដ្ឋាករ÷ ១០៦, ៨៥%<br>□ពន្ធដារ÷ ៩៩, ៣៤%<br>សម្រាប់ការអនុវត្តផែនការប្រមូលចំណូលមិនមែនសារពើពន្ធធៀបនឹងផែនការ÷<br>□ទ្រព្យសម្បត្តិរដ្ឋ÷ ១០៥,១៦%<br>ឧស្សាហកម្មហិរញ្ញវត្ថុ ÷១២៩, ៤៧% |
| **២. គ្មានការបង្កើតឡើងនូវបំណុលកកស្ទះថ្មី (គិតរយៈពេល៦០ថ្ងៃ)** | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២%នៃចំណាយសរុប | គ្មាន | គ្មាន |
| **៣. អាណាប័កជាបណ្តើរៗអាចបញ្ចូលចំណាយទៅតាមកម្មវិធីចំណាយនិងផែនការសាច់ប្រាក់** | ស្ថានភាពចំណាយមិនត្រូវតិចជាងៈ<br>□ត្រីមាសទី១: ១៥%<br>□ត្រីមាសទី២: ៤៥%<br>□ត្រីមាសទី៣: ៦៧%<br>□ត្រីមាសទី៤: ៩៦%<br><br>ភាគរយនៃការទូទាត់ជូនអ្នកផ្គត់ផ្គង់និងបុគ្គលិកតាមប្រព័ន្ធធនាគារមិនត្រូវតិចជាង៨០%នៃចំណាយសរុប | ចំណាយថវិកាជាតិសម្រេចបាន÷<br>□ត្រីមាសទី១: ១៥,១៦%<br>□ត្រីមាសទី២: ៣០,១០%<br><br>ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន÷<br>□ ត្រីមាសទី១: ១០០%<br>□ ត្រីមាសទី២: ១០០%<br>▪ ក្រសួងចំនួន ៣៦ ក្រសួង ស្ថាប័នបានបើកបៀវត្សតាមប្រព័ន្ធនាគារ | ចំណាយថវិកាជាតិសម្រេចបាន÷<br>□ត្រីមាសទី១: ១៤,៥៧%<br>□ត្រីមាសទី២: ៣២,៩៧%<br><br>ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន÷<br>□ ត្រីមាសទី១: ១០០%<br>□ ត្រីមាសទី២: ១០០%<br>▪ ក្រសួងចំនួន ៣៦ ក្រសួង ស្ថាប័នបានបើកបៀវត្សតាមប្រព័ន្ធនាគារ |

| សូចនាករ | គោលដៅ | វឌ្ឍនភាពត្រីមាសទី២ ឆ្នាំ២០១៥ | វឌ្ឍនភាពត្រីមាសទី២ ឆ្នាំ២០១៦ |
|---|---|---|---|
| | ភាគរយនៃការបង់ចំណូលតាមរយៈប្រព័ន្ធធនាគារមិនត្រូវតិចជាង ៦០%នៃចំណូលសរុប | **ត្រីមាសទី១÷**<br>-ចំណូលពន្ធគយ:<br>▪ ៩២% បង់តាមធនាគារដោយអតិថិជន<br>▪ ៨%បង់តាមធនាគារដោយគយ<br>-ចំណូលពន្ធដារ:<br>▪ ៩៨,៨% បង់តាមធនាគារដោយអតិថិជន<br>▪ ១,២%បង់តាមធនាគារដោយពន្ធដារ<br>**ត្រីមាសទី២÷**<br>-ចំណូលពន្ធគយ:<br>▪ ៩២,៦% បង់តាមធនាគារដោយអតិថិជន<br>▪ ៧,៤%បង់តាមធនាគារដោយគយ<br>-ចំណូលពន្ធដារ:<br>▪ ៨៥% បង់តាមធនាគារដោយអតិថិជន<br>▪ ១៥%បង់តាមធនាគារដោយពន្ធដារ | **ត្រីមាសទី១÷**<br>-ចំណូលពន្ធគយ:<br>▪ ៩៤,២% បង់តាមធនាគារដោយអតិថិជន<br>▪ ៥,៨% បង់តាមធនាគារដោយគយ<br>-ចំណូលពន្ធដារ:<br>▪ ៩៦,៩% បង់តាមធនាគារដោយអតិថិជន<br>▪ ៣,១%បង់តាមធនាគារដោយពន្ធដារ<br>**ត្រីមាសទី២÷**<br>-ចំណូលពន្ធគយ:<br>▪ ៩០,៤% បង់តាមធនាគារដោយអតិថិជន<br>▪ ៩,៦%បង់តាមធនាគារដោយគយ<br>-ចំណូលពន្ធដារ:<br>▪ ៩៩,៧% បង់តាមធនាគារដោយអតិថិជន<br>▪ ០,៣%បង់តាមធនាគារដោយពន្ធដារ |
| **៤. ចំណាយតាមប្រភេទ (សម្រាប់បុគ្គលិក) កាន់តែខិតទៅរកថវិកាដែលបានអនុម័ត** | លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង÷<br>□បៀវត្ស: **៩៨%**<br>□ទំនិញ/សេវា: **៩៥%**<br>□មូលធន: **៨៥%** | ចំណាយថវិកាជាតិសម្រេចបាន÷<br>ត្រីមាសទី១ ÷<br>□បៀវត្ស: ២២,៣៤%<br>□ទំនិញ/សេវា: ៨,៥៤%<br>□មូលធន: ១២,៧៥%<br>ត្រីមាសទី២ ឆ្នាំ២០១៥÷<br>□បៀវត្ស: ៤៤,៥៤%<br>□ទំនិញ/សេវា: ១៩,៦៨%<br>□មូលធន: ២៨,៩២% | ចំណាយថវិកាជាតិសម្រេចបាន:<br>ត្រីមាសទី១ ÷<br>□បៀវត្ស: ១៨,៦៤%<br>□ទំនិញ/សេវា: ៨,៨៨%<br>□មូលធន: ១៤,២៥%<br>ត្រីមាសទី២ ឆ្នាំ២០១៦÷<br>□បៀវត្ស: ៤២,១៥%<br>□ទំនិញ/សេវា: ២០,៣០%<br>□មូលធន: ២៧,៤៥% |
| **៥.ទិន្នផលចំណូលលើមូលដ្ឋានពន្ធកាន់តែប្រសើរជាងមុនតាមរយៈ ការកែលម្អប្រសិទ្ធភាពនៃការប្រមូល និងផែនការប្រើប្រាស់ប្រភពចំណូល មិនមែនសារពើពន្ធ** | ការរួមចំណែកទៅក្នុង ផ.ស.ស នៃចំណូល សរុបមានការកែលម្អដោយ បង្កើនប្រមាណ ០,៥% ក្នុងមួយឆ្នាំ | □ចំណូលសារពើពន្ធ÷ ៣១,៥%<br>• ពន្ធផ្ទាល់ : ៤៣,៥%<br>• ពន្ធប្រយោល : ២៤,១%<br>□ចំណូលមិនមែនសារពើពន្ធ : ១៨,៣% | □ចំណូលសារពើពន្ធ÷ ២៩,១%<br>• ពន្ធផ្ទាល់ : ៣៧,១%<br>• ពន្ធប្រយោល : ២៧,០%<br>□ចំណូលមិនមែនសារពើពន្ធ : ២៥,៣% |

| សូចនាករ | គោលដៅ | វឌ្ឍនភាពត្រីមាសទី២ ឆ្នាំ២០១៥ | វឌ្ឍនភាពត្រីមាសទី២ ឆ្នាំ២០១៦ |
|---|---|---|---|
| **៦. រាល់ផ្នែកសំខាន់ៗនៃចំណូល និងចំណាយសាធារណៈត្រូវបានដាក់បញ្ចូលក្នុងថវិកានិងគណនីរបស់រដ្ឋាភិបាល** | មិនមានផ្នែកសំខាន់ៗដែលត្រូវបានដកចេញ | មានចំនួនគណនីសរុប÷ ៨២ គណនី | មានចំនួនគណនីសរុប÷ ៨៣ គណនី |

បំណកស្រាយលទ្ធផលនៃការអនុវត្តសូចនាករ÷

**ក. ការអនុវត្តការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ**

- **អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាអនុវត្តបាន ១.៧៧៥.៩១៦ លានរៀលខ្ពស់ជាងផែនការប្រចាំត្រីមាសទី២ ប្រមាណ ៦,៨៥% ដែលស្មើនឹង ២៦,៧១% នៃច្បាប់ថវិកាឆ្នាំ២០១៦។ ប្រសិនបើធៀបការអនុវត្តប្រចាំត្រីមាសទី២ ឆ្នាំ២០១៦ និងត្រីមាសទី២ ឆ្នាំ២០១៥ ការអនុវត្តចំណូលមានការកើនឡើង១៥,៦៤%។ តាមរយៈទិន្នន័យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ កម្ពុជា (ដោយគិតតែចំណូលសារពើពន្ធ) តួលេខនៃការបង់ចំណូលគយចូលរតនាគារជាតិក្នុងត្រីមាសទី២ ឆ្នាំ២០១៦ នេះ សម្រេចបាន ១.៧៧៦.០៦៨ លានរៀល ខ្ពស់ជាងផែនការ ៦,៨៦% ដោយសារការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវការត្រួតពិនិត្យដើមទី កណ្តាលទី និងចុងទី និងបានដាក់ឱ្យអនុវត្តផែនការសកម្មភាពនៃការប្រមូលពន្ធអាករ និងប្រាក់ពិន័យលើយានយន្តមានស្រាប់ក្នុងប្រទេសដែលមិនបានបំពេញកាតព្វកិច្ចពន្ធនិងអាករ និងការកែសម្រួលអត្រាអាករពិសេសដែលចូលជាធរមាននៅខែមេសា ឆ្នាំ២០១៦។

- **អគ្គនាយកដ្ឋានពន្ធដារ**

យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានពន្ធដារ(ចំណូលសារពើពន្ធថ្នាក់ជាតិ) អនុវត្តបាន ១,៥៩២,១៩៩ លានរៀល ស្មើនឹង ៩៩,៣៤% នៃផែនការប្រចាំត្រីមាសទី២ ឬ ស្មើ ២៨%នៃច្បាប់ថវិកា។ ប្រសិនបើធៀបការអនុវត្តប្រចាំត្រីមាសទី២ ឆ្នាំ២០១៦ និងត្រីមាសទី២ ឆ្នាំ២០១៥ ការអនុវត្តចំណូលមានការកើនឡើង ១៥,៩៩%។ តាមរយៈទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ដោយគិតតែចំណូលសារពើពន្ធថ្នាក់ជាតិ) តួលេខនៃការបង់ចំណូលពន្ធដារចូលរតនាគារជាតិក្នុងត្រីមាសទី២ ឆ្នាំ២០១៦នេះ សម្រេចបាន ១.៥៨៦.៦៨៦.៨ លានរៀល ដែលស្មើ ៩៩% នៃផែនការប្រចាំត្រីមាសទី២ ឬស្មើ ២៧.៩០% នៃច្បាប់ថវិកា។ ការពង្រឹងការអនុវត្តច្បាប់ពន្ធដារ និងពង្រឹងការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូល និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជំរុញឱ្យចំណូលពន្ធដារមានកំណើនជាលំដាប់។

- **ចំណូលមិនមែនសារសារពើពន្ធ**

យោងតាមទិន្នន័យរបស់អគ្គនាយដ្ឋានរតនាគារជាតិ (ដោយមិនបញ្ចូលចំណូលពីអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ) ចំណូលមិនមែនសារពើពន្ធអនុវត្តបាន ៤៣៨.៦៥០ លានរៀល កើនលើសផែនការ ៥.១៦% ឬស្មើនឹង២៥.៥៤% នៃច្បាប់ថវិកាឆ្នាំ២០១៦។ ប្រសិនបើធៀបការអនុវត្តប្រចាំត្រីមាសទី២ ឆ្នាំ២០១៦ និងការអនុវត្តត្រីមាសទី២ ឆ្នាំ២០១៥ ចំណូលមានកំណើន ៦៣,៤០%។ ការកើនឡើងនៃចំណូលមិនមែនសារពើពន្ធ គឺក្រសួង ស្ថាប័នពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ដូចជាការពង្រឹងការតឹងទារបំណុល និងជំរុញឱ្យការបង់ចំណូលឱ្យបានទាន់ពេលវេលា។

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុមានប្រភពចំណូលចំនួន ៣ គឺ (១) ចំណូលកាតព្វកិច្ចពីកាស៊ីណូ, (២) ចំណូលកាតព្វកិច្ចពីឆ្នោត និង (៣) ចំណូលពីអាជ្ញាបណ្ណកាស៊ីណូ។ យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ (មិនគិតបញ្ចូលចំណូលមកពីអាជ្ញាប័ណ្ណ ដោយចំណូលនេះ ត្រូវដាក់ក្នុងចំណូលអាជ្ញាប័ណ្ណជាមួយក្រសួង ស្ថាប័ន), ចំណូលប្រមូលបានចំនួន ២៩.៥៥០លានរៀល ខ្ពស់ជាងផែនការ ២៩.៤៧% ឬ ស្មើនឹង២១.៩១% នៃច្បាប់ថវិកា។ ការកើនឡើងនៃចំណូល ដោយការរឹតបន្តឹងការចុះត្រួតពិនិត្យបណ្តារកាស៊ីណូ និងការជំរុញឱ្យបង់ចំណូលប្រចាំខែបានទាន់ពេលវេលា ជាពិសេសកាស៊ីណូដែលបង់ម្តងមួយត្រីមាស។

## ខ. បំណុលកកស្ទះ

គ្មានការបង្កើតឡើងនូវបំណុលកកស្ទះថ្មី បើគិតរយៈពេល៦០ថ្ងៃ ចាប់ពីអាណត្តិបើកផ្តល់ប្រាក់បានចូលរតនាគារជាតិរហូតដល់ថ្ងៃទូទាត់។ នេះបង្ហាញថាដំណើរការទូទាត់ និងស្ថានភាពសាច់ប្រាក់ មានលក្ខណៈល្អប្រសើរជាងមុន និងខិតជិតទៅរកនិយាមអន្តរជាតិនៃការកំណត់បំណុលកកស្ទះ។

## គ. ចំណាយថវិកាជាតិ

ការអនុវត្តចំណាយសម្រាប់ត្រីមាសទី២ គឺសម្រេចបាន ៣២,៩៧% នៃច្បាប់ថវិកា ពោលគឺទាបជាង ១២,០៣%។ ក្រសួង-ស្ថាប័នមួយចំនួន ដែលអនុវត្តថវិកាសម្រាប់ត្រីមាសទី២ បានតិចជាងគោលដៅ ៤៥% ធៀបនឹងច្បាប់ថវិកា មានដូចតទៅ÷

១. ក្រសួងមុខងារសាធារណៈ អនុវត្តបាន ២១,០៤%
២. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុវត្តបាន ៣,៧៦%
៣. ក្រសួងមហាផ្ទៃ (រដ្ឋបាលទូទៅ) អនុវត្តបាន ២៨,២៣%
៤. ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អនុវត្តបាន ៣១,៨៣%
៥. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុវត្តបាន ៤២,៥៣%
៦. ក្រសួងផែនការ អនុវត្តបាន ៣១,០៩%
៧. ក្រសួងយុត្តិធម៌ អនុវត្តបាន ១៧,៦៣%
៨. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុវត្តបាន ៣,៨៩%
៩. អាជ្ញាធរសវនកម្មជាតិ អនុវត្តបាន ២៨,២៩%

១០. អង្គភាពប្រឆាំងអំពើពុករលួយ អនុវត្តបាន ៣៧,៩២%

១១. ក្រសួងការពារជាតិ អនុវត្តបាន ៤៣,០៩%

១២. ក្រសួងមហាផ្ទៃ (សន្តិសុខសាធារណៈ) អនុវត្តបាន ៤៣,៣៣%

១៣. ក្រសួងព័ត៌មាន អនុវត្តបាន ៣៩,៣២%

១៤. ក្រសួងសុខាភិបាល អនុវត្តបាន ៣៥,២៤%

១៥. ក្រសួងអប់រំ យុវជន និងកីឡា ៣៣,៣៦%

១៦. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុវត្តបាន ២៤,២៤%

១៧. ក្រសួងបរិស្ថាន អនុវត្តបាន ២៤,៥៧%

១៨. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុវត្តបាន ៤១,៤៥%

១៩. ក្រសួងធម្មការ និងសាសនា អនុវត្តបាន ២៧,៥០%

២០. ក្រសួងកិច្ចការនារី អនុវត្តបាន ២៨,៣៣%

២១. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តបាន ១៥,៣៦%

២២. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុវត្តបាន ៨,៣៣%

២៣. ក្រសួងរ៉ែ និងថាមពល អនុវត្តបាន ១៨,៨៤%

២៤. ក្រសួងពាណិជ្ជកម្ម អនុវត្តបាន ១៨,១៦%

២៥. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុវត្តបាន ២០,៤៩% ២៦. ក្រសួងអភិវឌ្ឍន៍ជនបទ អនុវត្តបាន ៧,៧៩%

២៧. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អនុវត្តបាន ១៧,៩៤%

២៨. ក្រសួងសាធារណៈការ និងដឹកជញ្ជូន អនុវត្តបាន ១០,៧១%

២៩. ក្រសួងទេសចរណ៍ អនុវត្តបាន ៣២,១០%

៣០. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តបាន ១៩,៣៥%

៣១. ក្រសួងធនធានទឹក និងឧតុនិយម អនុវត្តបាន ៦,៨០%

៣២. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម អនុវត្តបាន ២៥,៦០%។

ដោយឡែក រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត, ក្រុង-ស្រុក និងឃុំ-សង្កាត់) អនុវត្តបាន ១៩,០១%។

### ឃ. ចំណាយតាមប្រភេទ

ចំណាយតាមប្រភេទសម្រេចបាន ដូចតទៅ÷ បៀវត្ស មាន ៤២,១៥%, ទំនិញ/សេវា មាន ២០,៣២% និង មូលធន មាន ២៧,៤៥%។

## ៣. វឌ្ឍនភាពតាមផ្នែក

### ៣.១. ផ្នែកទី១÷ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា (៨០%)

ភាពជឿទុកចិត្តនៃថវិកា គឺសំដៅសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តថវិកា ដើម្បីសម្រេចបាននូវរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការងារពង្រឹងភាពជឿទុកចិត្តនៃថវិកា នៅតែត្រូវបានបន្តអនុវត្តនៅក្នុងដំណាក់កាលទី៣ គឺមានគោលដៅចម្បងឈានទៅរកប្រព័ន្ធដ៏រឹងមាំនិងប្រកបដោយស្ថិរភាព ជាពិសេស ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់សម្រាប់ (១) ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាសមានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនលើសពី +/-៥% ធៀបទៅនឹងកម្មវិធីចំណូល-ចំណាយ) និង (២) ការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព។

សម្រាប់ត្រីមាសទី២ ផ្នែកទី១÷ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា (សម្រេចបាន ៨០%) ដោយមានគោលបំណងចំនួន ៤ និងចង្កោមសកម្មភាពចំនួន ៩ អនុវត្តដោយ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គលេខាធិការដ្ឋាន កសហវ និងក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ (FMWG)។

#### ៣.១.១. គោលបំណង១១÷ការបន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល (៧៧%)

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល (ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ) ការរៀបចំគោលនយោបាយចំណូល និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម គឺជាកត្តាគន្លឹះដើម្បីធានានូវការលុបបំបាត់ឱនភាពសាច់ប្រាក់ទាំងស្រុង, ភាពរលូននៃលំហូរចំណូល និងប៉ាន់ប្រមាណបាន។

គោលបំណងនេះមាន ០៣ ចង្កោមសកម្មភាព ដែលត្រូវអនុវត្តដោយ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយក-ដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋាននៃ កសហវ។ ជាក់ស្តែង គោលបំណងនេះសម្រេចបាន ៧៧% ក្នុងនោះ ចង្កោមសកម្មភាព ១១.១.អនុវត្តគោលនយោបាយចំណូលរយៈពេលមធ្យម និងយុទ្ធសាស្ត្រកៀរគរចំណូល ៨៦%, ១១.២ បន្តកែលម្អគោលនយោបាយនិងរដ្ឋបាលគយ, ពន្ធដារ និងចំណូលមិនមែនសារពើពន្ធនិងទ្រព្យសម្បត្តិរដ្ឋ ៨១%, ១១.៣. ពង្រឹងការព្យាករចំណូល ៦៣%។

<u>**ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷**</u>

១. ការចុះត្រួតពិនិត្យគ្រប់សកម្មភាពអាជីវកម្មជាប្រចាំនិង របាយការណ៍ត្រួតពិនិត្យចំណូលប្រចាំត្រីមាសទី២ ត្រូវបានរៀបចំបញ្ចប់

២. ការអនុវត្តប្រកាសអន្តរក្រសួងរវាង កសហវ និងក្រសួងមហាផ្ទៃ និងលិខិតបទដ្ឋានគតិយុត្តនានាត្រូវបានពង្រឹងនិងអនុវត្ត ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ចំពោះអាជីវកម្មល្បែងស៊ីសងគ្រប់

ប្រភេទព្រមទាំងអាជីវកម្ម បញ្ចាំ និងប្រតិភោគដោយអនុប្បទានដែលពុំមានអាជ្ញាបណ្ណនៅខេត្តស្វាយរៀង ខេត្តរតនគីរី និងខេត្តកណ្តាល

៣. សេចក្តីព្រាងច្បាប់ស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងឧស្ម័ន, និងធនធានរ៉ែធម្មជាតិ ដូចជាមាស ត្បូងថ្ម ទង់ដែង ត្រូវបានរៀបចំបញ្ចប់កម្រិត អគ្គ.ពន្ធដារ ដោយមានធាតុពីក្រសួងពាក់ព័ន្ធ

៤. ការសិក្សាស្រាវជ្រាវរៀបចំបទប្បញ្ញត្តិនានាស្តីពីពន្ធលើចំណូលបុគ្គល (Personal Income Tax) ត្រូវបានបញ្ចប់កម្រិតក្រុមការងារបច្ចេកទេស

៥. សេចក្តីព្រាងប្រកាសស្តីពីការបំពេញបន្ថែមកាតព្វកិច្ចសារពើពន្ធចំពោះសហគ្រាស ដែលអនុវត្តគម្រោងច្រើន (Multi QIP) ត្រូវបានបញ្ចប់កម្រិតក្រុមការងារបច្ចេកទេស និងគ្រោងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ

៦. ៤០ សហគ្រាស ត្រូវបានផ្ទេរជាអ្នកជាប់ពន្ធពីរបបម៉ៅការទៅស្វ័យប្រកាសក្នុងត្រីមាសទី២ និងកំពុងបន្តតាមដាន និងត្រួតពិនិត្យការផ្ទេរអ្នកជាប់ពន្ធតាមសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់

៧. សេចក្តីព្រាងសារាចរណែនាំស្តីពី ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបានរៀបចំ

៨. ទិន្នន័យចំណូលពន្ធដារត្រូវបានប្រមូលផ្តុំនិងចងក្រងជាមូលដ្ឋានសម្រាប់គំរូព្យាករណ៍។

**<u>រីឯសូចនាករមិនសម្រេចបានតាមគោលដៅ គឺ៖</u>**

១. (១១.១.១៩.) សារាចរណែនាំស្តីពី ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់និងកម្រៃសេវាសាធារណៈជាមួយក្រសួងទេសចរណ៍ និង រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវបានកែសម្រួល **៨0%**

២. (១១.២.១.) សេចក្តីព្រាងវិធានការគៀគរចំណូលគយដើម្បីប៉ះប៉ូវចំណូលដែលបាត់បង់ **២៥%**

៣. (១១.២.៧.) សេចក្តីព្រាងប្រកាសស្តីពីការអនុវត្តច្បាប់ស្តីពីសារពើពន្ធ មាត្រា ១១១ ពាក់ព័ន្ធនឹងការរឹបអូស និងលក់ទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលជំពាក់ប្រាក់ពន្ធ ហើយមិនព្រមចូលខ្លួនមកបង់ពន្ធ ត្រូវបានពិនិត្យសម្រេចកម្រិតក្រុមការងារ **៨0%**

៤. (១១.២.១៦.) បញ្ជរពិគ្រោះយោបល់ពន្ធត្រូវបានដាក់ឱ្យប្រើប្រាស់ ៣ សាខាពន្ធដារ **៧0%**

៥. (១១.២.២១.) សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋត្រូវបានពិនិត្យនិងសម្រេចដោយ កសហវ **២៥%**

៦. (១១.២.២២.) សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានប្រជុំពិភាក្សាកម្រិត កសហវ 0%។

ដោយឡែក ការងារផ្តល់មតិប្រឹក្សាច្បាប់លើលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអនុវត្តយុទ្ធសាស្ត្រគៀគរចំណូលរយៈពេលមធ្យមឆ្នាំ ២០១៤-២០១៨ (សកម្មភាព ១១.១.២៧) អគ្គលេខាធិការដ្ឋាននៃ កសហវ បានស្នើផ្លាស់ប្តូរសូចនាករទៅជា *"ផ្តល់មតិប្រឹក្សាច្បាប់ តាមរយៈពេលដូចតទៅ៖*

*១. ក្រោម ១០ ប្រការ/មាត្រា៖ ២ សប្តាហ៍*

*២. ពី ១០ ទៅ ៣០ ប្រការ/មាត្រា៖ ៣ សប្តាហ៍*

*៣. ពី ៣០ ទៅ ៦០ ប្រការ/មាត្រា÷ ៤ សប្តាហ៍*

*៤. ពី ៦០ ទៅ ១០០ ប្រការ/មាត្រា÷ ៥ សប្តាហ៍*

*៥. ពី ១០០ ប្រការ/មាត្រាឡើងទៅ÷ ៦ សប្តាហ៍"*

ការស្នើសុំផ្លាស់ប្តូរសូចនាករនេះ គឺដោយហេតុថា សូចនាករដែលបានកំណត់ពីមុន មិនផ្តល់នូវភាពជាម្ចាស់ដល់អគ្គលេខាធិការដ្ឋាន គសហវ នោះឡើយ ហើយការសម្រេចជោគជ័យនៃសូចនាករនេះ គឺអាស្រ័យទាំងស្រុងលើវឌ្ឍនភាព និងការកំណត់អាទិភាពនៃអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ។

**៣.១.២. គោលបំណង១២÷ ការបន្តពង្រឹងការគ្រប់គ្រងបំណុល (៨៣%)**

ការគ្រប់គ្រងបំណុលសាធារណៈ សំដៅដល់ការគ្រប់គ្រងលើរាល់ប្រតិបត្តិការរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការខ្ចីប្រាក់ពីគេ, ការឱ្យប្រាក់គេខ្ចី, ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋ, ការបោះផ្សាយនិងដាក់លក់បណ្ណរដ្ឋអធិបតេយ្យ, ការធានា, ការតព្វកិច្ចបំណុលជាយថាហេតុ, ការទូទាត់សេវាបំណុល, ការរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ, ការគ្រប់គ្រងហានិភ័យ, ការវិនិយោគដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា និងប្រតិបត្តិការផ្សេងៗទៀតពាក់ព័ន្ធនឹងបំណុលសាធារណៈ។

គោលបំណងនេះមាន ០៣ ចង្កោមសកម្មភាព ដែលត្រូវអនុវត្តដោយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានថវិកា និងអគ្គលេខាធិការដ្ឋាន គសហវ។ ជាក់ស្តែង គោលបំណងនេះសម្រេចជារួម ៨៣% ក្នុងនោះ ចង្កោមសកម្មភាព ១២.១. អនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ១០០%, ១២.២. រៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការសម្រាប់អនុវត្តការធានារបស់រដ្ឋ ៧៥%, ១២.៣. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលត្រូវទារក្នុងឆ្នាំ ៧៣%។

<u>**ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷**</u>

១. សេចក្តីព្រាងស្តង់ដារនីតិវិធីប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានរៀបចំ

២. មន្ត្រីបំណុលពន្ធនៅតាមនាយកដ្ឋាន/សាខាពន្ធដារខេត្ត/ខណ្ឌ ត្រូវបានបណ្តុះបណ្តាល ១លើកពីការគ្រប់គ្រងនិងការប្រមូលបំណុលពន្ធ។

<u>**រីឯសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷**</u>

១. (១២.២.១.)សេចក្តីព្រាងគោលនយោបាយស្តីពីការធានារបស់រដ្ឋត្រូវបានកែលម្អ និងធ្វើសិក្ខាសាលាពិគ្រោះយោបល់ **៥០%**

២. (១២.២.២.)មតិប្រឹក្សាច្បាប់លើលិខិតបទដ្ឋានគតិយុត្តសម្រាប់រៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការសម្រាប់អនុវត្តការធានារបស់រដ្ឋត្រូវបានផ្តល់ជូនតាមផែនការ **៥០%**

៣.(១២.៣.២.)សេចក្តីព្រាងសៀវភៅណែនាំស្តីពីសវនកម្មផ្ទៃក្នុង ត្រូវបានពិនិត្យសម្រេចកម្រិតអគ្គ.ពន្ធដារ **៨០%**។

ដោយឡែក ការងារផ្តល់មតិប្រឹក្សាច្បាប់លើលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព (សកម្មភាព ១២.២.២) អគ្គលេខាធិការដ្ឋាន គសហវ បានស្នើប្តូរសូចនាករទៅជា *"ផ្តល់មតិប្រឹក្សាច្បាប់ តាមរយៈពេលដូចតទៅ÷*

*១. ក្រោម ១០ ប្រការ/មាត្រា÷ ២ សប្តាហ៍*

*២. ពី ១០ ទៅ ៣០ ប្រការ/មាត្រា÷ ៣ សប្តាហ៍*

*៣. ពី ៣០ ទៅ ៦០ ប្រការ/មាត្រា÷ ៤ សប្តាហ៍*

*៤. ពី ៦០ ទៅ ១០០ ប្រការ/មាត្រា÷ ៥ សប្តាហ៍*

*៥. ពី ១០០ ប្រការ/មាត្រាឡើងទៅ÷ ៦ សប្តាហ៍"*

ការស្នើសុំផ្លាស់ប្តូរសូចនាករនេះ គឺដោយហេតុថា សូចនាករដែលបានកំណត់ពីមុន មិនផ្តល់នូវភាពជាម្ចាស់ដល់ អគ្គលេខាធិការដ្ឋាន កសហវ នោះឡើយ ហើយការសម្រេចជោគជ័យនៃសូចនាករនេះ គឺអាស្រ័យទាំងស្រុងលើវឌ្ឍនភាពនិងការកំណត់អាទិភាពនៃអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ។

### ៣.១.៣. គោលបំណង១៣÷ ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី (៩៤%)

ការគ្រប់គ្រងសាច់ប្រាក់ គឺសំដៅដល់ធានាឱ្យបានមានសាច់ប្រាក់គ្រប់គ្រាន់ក្នុងធនាគារ ដើម្បីទូទាត់ចំណាយបានទាន់ពេលវេលា និងពង្រឹងការគ្រប់គ្រងគណនីទោលរតនាគារ។ ការគ្រប់គ្រងសាច់បានល្អ ត្រូវមាន (១) ការព្យាករណ៍លំហូរសាច់ប្រាក់អាចទុកចិត្តបាន, (២) មានប្រព័ន្ធកត់ត្រាប្រតិបត្តិការសាច់ប្រាក់បានត្រឹមត្រូវ និង (៣) ការប្រើប្រាស់សាច់ប្រាក់សម្រាប់វិនិយោគ។

គោលបំណងនេះមាន ០៥ ចង្កោមសកម្មភាព ដែលត្រូវអនុវត្តដោយ អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានថវិកា និងក្រុមការងារគ្រប់គ្រងគម្រោង FMIS។ ជាក់ស្តែង គោលបំណងនេះសម្រេចបាន ៩៤% ក្នុងនោះ ចង្កោមសកម្មភាព ១៣.១. បន្តកែលម្អ និងពង្រឹងការរៀបចំផែនការសាច់ប្រាក់ (៩៨%), ១៣.២. បន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធធនាគារព្រមទាំងសិក្សា និងពិនិត្យលទ្ធភាពឈានទៅអនុវត្តការទូទាត់តាម E-Transfer (៦៣%), ១៣.៣. រៀបចំយន្តការប្រមូលផ្តុំនិងប្លុកសរុបរបាយការណ៍អនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ដែលនៅក្រៅប្រព័ន្ធរតនាគារជាជំហានៗ និងបន្តពង្រឹងគណនីទោលរតនាគារ សម្រេចបាន (១០០%), ១៣.៤. បន្តតាមដានបំណុលកកស្ទះ និងអាយុកាលរបស់វា (១០០%), ១៣.៥. ទូទាត់បុរេប្រទានឱ្យបានទាន់ពេលវេលា (១០០%)។

**<u>ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷</u>**

១. ស្ថានភាពសាច់ប្រាក់ ត្រូវបានតាមដាន ពិនិត្យ ព្យាករណ៍ជាប្រចាំ និងបានកែលម្អជាបន្តបន្ទាប់

២. ស្ថានភាពចំណូលនិងចំណាយរបស់ក្រសួង ស្ថាប័ន ជាប្រចាំ (តាមរយៈឯកសារជា Hard copy) ត្រូវបានប្រមូល តាមដាន ពិនិត្យ និងព្យាករណ៍ និងឈានទៅប្រើប្រាស់តួលេខក្នុងប្រព័ន្ធ (CMS)

៣. ការទូទាត់ចំណាយតាមរយៈប្រព័ន្ធ FMIS និង ប្រព័ន្ធរបស់ NBC ត្រូវបានបន្តសាកល្បងអនុវត្ត ដើម្បីឈានដល់ការអនុវត្តតាមប្រព័ន្ធ E-Transfer

៤. គណនីដែលបើកនិងប្រើប្រាស់នៅតាមធនាគារជាដៃគូ (ធនាគារពាណិជ្ជនៅថ្នាក់កណ្តាល និងថ្នាក់រាជធានីខេត្ត) ត្រូវបានពិនិត្យ និងតាមដាន។

### ៣.១.៤.គោលបំណង១៤÷ ការកែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ (៧២%)

ការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺមានកម្រិតលម្អៀង ធៀបនឹងច្បាប់ថវិកាស្ថិតក្នុងចន្លោះ +/-៥%។ ការអនុវត្តថវិកាសម្រេចឱ្យបានតាមគោលដៅ គឺទាមទារឱ្យកែលម្អនីតិវិធីអនុវត្ត និងពង្រឹងការរៀបចំកម្មវិធីចំណូល-ចំណាយ។

គោលបំណងនេះមាន ០៣ ចង្កោមសកម្មភាព ដែលត្រូវអនុវត្ត អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គលេខាធិការដ្ឋាននៃកសហវ, និងក្រុមការងារគ្រប់គ្រងគម្រោង FMIS។ ជាក់ស្តែង គោលបំណងនេះសម្រេចបានជារួម ៧១% ក្នុងនោះ ចង្កោមសកម្មភាព ១៤.១. ការធ្វើសុខដុមនីយកម្មរវាងការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ (IRRPP) និងស្តង់ដារនីតិវិធីរួម (SOP/PM) ៤៦%, ១៤.២ បង្កើនការប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការលទ្ធកម្មដោយមានការចូលរួមជាសាធារណៈ ៤៨%, ១៤.៣. រៀបចំផែនការចំណាយប្រចាំត្រីមាសឱ្យមានសុក្រឹតភាព ១០០%។

**<u>ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷</u>**

១. វិធីសាស្រ្តក្នុងការរៀបចំកម្មវិធីចំណាយត្រូវបានពិនិត្យនិងកែលម្អ

២. វិធាននិងនីតិវិធីនៃការអនុវត្តកម្មវិធីចំណូល-ចំណាយ ប្រចាំត្រីមាស ប្រចាំឆ្នាំ ត្រូវបានផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តដល់គ្រប់អង្គភាពថវិកានៃ កសហវ

៣. ប្រព័ន្ធកត់ត្រាអនុវត្តចំណាយថវិកាកម្មវិធី តាមចង្កោមសកម្មភាព របស់ អង្គភាពថវិកា កសហវ ត្រូវបានផ្សព្វផ្សាយណែនាំ និងដាក់ឱ្យអនុវត្ត។

**<u>រីឯសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷</u>**

១. (១៤.២.២.)សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ា និងវិវាទលទ្ធកម្មត្រូវបានអនុម័តដោយ គណៈរដ្ឋមន្ត្រី (COM) **៧០%**

២. (១៤.២.៣.)ប្រកាសចំនួន ០៦ ត្រូវបានបង្កើតនិងបន្តរៀបចំ រួមមាន÷ (១) ប្រកាសស្តីពីបុរេលក្ខណៈសម្បត្តិអ្នកដេញថ្លៃ, (២) ប្រកាសស្តីពី ការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកដេញថ្លៃ , (៣) ប្រកាសស្តីពីនីតិវិធីវាយតម្លៃសំណើដេញថ្លៃ , (៤) ប្រកាសស្តីពីវិធីនៃការចុះការជម្រះ និងការ ផ្សព្វផ្សាយបញ្ជីខ្មៅ , (៥)ប្រកាសស្តីពីពីបែបបទ និងនីតិវិធីនៃការប្តឹងនិងការដោះស្រាយបណ្តឹង តវ៉ានិងវិវាទលទ្ធកម្ម (៦) ប្រកាសស្តីពីការគ្រប់គ្រងកិច្ចសន្យា **៦៥%**

៣.(១៤.២.៨.)សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តស្តីពី កិច្ចសម្របសម្រួលរវាងអង្គភាពថវិកា និងអង្គភាពហិរញ្ញវត្ថុក្នុងការរៀបចំផែនការលទ្ធកម្ម ត្រូវបានរៀបចំ **0%**

៤. (១៤.២.៩.)ក្រុមលទ្ធកម្មរបស់អង្គភាពថវិកាចំនួន ៣១ មានការយល់ដឹងអំពីគោលការណ៍វិធាន វិធីសាស្រ្ត និងនីតិវិធីលទ្ធកម្ម នៃ កសហវ **0%**។

### ៣.២. ផ្នែកទី២ ÷ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ (៨២%)

ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ សំដៅលើគណនេយ្យភាពដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ស្របតាមច្បាប់និងគោលការណ៍ហិរញ្ញវត្ថុសាធារណៈ។ ដើម្បីធានាបាននូវគណនេយ្យភាពហិរញ្ញវត្ថុ ការរៀបចំប្រព័ន្ធតាមដាន, កត់ត្រា និងការរៀបចំរបាយការណ៍ ដោយសុក្រឹត្យ និងទាន់ពេលវេលា គឺជាកម្មវត្ថុចំបងសម្រាប់ជំហានទី២។

ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ មានន័យថា ការទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាលរបស់ ក្រសួង-ស្ថាប័ន គឺជាការងារចាំបាច់ក្នុងការអនុវត្តថវិកា និងការងារហិរញ្ញវត្ថុ និងការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុជាសារវន្តត្រូវតែសម្រេចឱ្យបាន និងត្រូវបន្តអនុវត្តនៅក្នុងដំណាក់កាលទី៣ ទន្ទឹមនឹងការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ឆ្ពោះទៅរកប្រព័ន្ធដ៏រឹងមាំ និងប្រកបដោយស័ក្តិភាព។ ទន្ទឹមនេះ ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ គឺជាគោលដៅចម្បងនៃដំណាក់កាលទី៣នេះ ដែលផ្តោតសំខាន់ទៅលើ (១) ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី (២) ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិថ្មី (៣) ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព និង (៤) ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព (ប្រព័ន្ធត្រួតពិនិត្យ)។

សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៦ ផ្នែកទី២÷ ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ (សម្រេចបាន ៨២%) ត្រូវបានបន្តអនុវត្ត ដោយមានគោលបំណងចំនួន ៤ និងចង្កោមសកម្មភាពចំនួន ១៤ ហើយមានសកម្មភាពគ្រោងអនុវត្តដោយអគ្គនាយកដ្ឋានចំនួន ០៧ រួមមាន អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គលេខាធិការដ្ឋាន កសហវ, អគ្គាធិការដ្ឋាន, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, ក្រុមការងារ FMIS។

#### ៣.២.១. គោលបំណង២១÷ ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី (៩២%)

ការអនុវត្តមាតិថវិកាថ្មី និងប្លង់គណនេយ្យថ្មី ត្រូវបន្តកែលម្អដើម្បីធានាឱ្យមានសង្គតិភាពនិងអនុវត្តនិងស្តង់ដារអន្តរជាតិចំណាត់ថ្នាក់។ ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ៩២% និងមានចង្កោមសកម្មភាពតែ ០១ទេ អនុវត្តដោយ អគ្គនាយកដ្ឋានគ្គនាយកដ្ឋានរតនាគារជាតិ ២១.១ បន្តកែលម្អប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់ថវិកាថ្មី (ភូមិសាស្ត្រ, អង្គភាពប្រតិបត្តិ និងរដ្ឋបាល, កម្មវិធី និងសេដ្ឋកិច្ច) និងអនុវត្តចំណាត់ថ្នាក់ ០៣ បន្ថែមទៀត (មុខងារ, មូលនិធិ និងគម្រោង) ៩២%។

<u>**ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷**</u>

១. របាយការណ៍ពិនិត្យ និងតាមដានកែសម្រួលចំណាត់ថ្នាក់សេដ្ឋកិច្ចត្រូវបានដាក់ប្រជុំនិងពិនិត្យ
២. ការកែសម្រួលចំណាត់ថ្នាក់កម្មវិធីត្រូវបានពិនិត្យនិងកែលម្អ (ការចរចាថវិកា) និងដាក់ប្រជុំ
៣. ឧបសម្ព័ន្ធនៃចំណាត់ថ្នាក់អង្គភាពប្រតិបត្តិនិងរដ្ឋបាលលើកទី២ ត្រូវបានប្រជុំនិងពិនិត្យរៀបចំ
៤. ប្លង់គណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗត្រូវបានពិនិត្យ និងរៀបចំប្រកាសដាក់ឱ្យអនុវត្ត, ប្លង់គណនេយ្យរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (បជស), អាជ្ញាធរអប្សរា និងមូលនិធិជនពិការបានរៀបចំរួច, និង ប្រកាសបំពេញបន្ថែមជំពូក

គណនី អនុគណនី សន្និធិសម្រាប់រៀបចំប្លង់គណនេយ្យគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានរៀបចំ។

**វឹងសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷**

១. (២១.១.១០.)រតនាគាររាជធានីខេត្ត ពី គណនី អនុគណនីថ្មី ដែលប្រើប្រាស់ក្នុងប្រព័ន្ធ FMIS ត្រូវបានជូនដំណឹងនិងផ្សព្វផ្សាយ តាមរយៈការបណ្ដុះបណ្ដាល ៥០%។

**៣.២.២.គោលបំណង២២÷ ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី (៨៤%)**

ការងារពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងប្រតិបត្តិការថ្មី គឺមានគោលដៅបន្តកាត់បន្ថយពេលវេលាសម្រាប់សំណើសុំធានាចំណាយ និងការទូទាត់នៅតាម ក្រសួង-ស្ថាប័ន និងកែលម្អប្រតិបត្តិការនៅក្នុង កសហវ ដោយពង្រឹងការអនុវត្តប្រព័ន្ធថវិកាថ្មី តាមរយៈការបង្កើនកម្រិតយល់ដឹង, ភាពជាម្ចាស់, ការចូលរួម និងសមត្ថភាពផ្នែក FMIS ទាំង កសហវ និង ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ៨៤% និងមានចង្កោមសកម្មភាពចំនួន ០៥ អនុវត្តដោយអគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គលេខាធិការ កសហវ និង ក្រុមការងារ FMWG ក្នុងនោះ ចង្កោមសកម្មភាព ២២.១ បន្តកាត់បន្ថយពេលវេលាសម្រាប់សំណើសុំធានាចំណាយនិងការទូទាត់នៅតាមក្រសួង-ស្ថាប័ន ៧៧% ២២.២ កែលម្អប្រតិបត្តិការនៅក្នុងកសហវ ក្រសួង ស្ថាប័ន ដើម្បីឱ្យស្របទៅនឹងការវិវឌ្ឍនៃប្លង់គណនេយ្យ និងបទដ្ឋានគណនេយ្យ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ ៩៥%, ២២.៣ បង្កើនកម្រិតយល់ដឹង, ភាពជាម្ចាស់, ការចូលរួម និងសមត្ថភាពផ្នែក FMIS ទាំងកសហវ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៩០%, ២២.៤ កសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS ដោយរួមទាំងនៅ កសហវ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ១០០%, និង ២២.៥ អនុវត្តសាកល្បងជំហានដំបូងនិងពង្រីកការអនុវត្ត FMIS (ម៉ូឌុលស្នូល និងម៉ូឌុល សម្រាប់ថវិកា និងពង្រីកការអនុវត្ត FMIS ទៅក្រសួង-ស្ថាប័ន) ៧២%។

**ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷**

១. សេចក្តីព្រាងក្របខណ្ឌរយៈពេលខ្លី និងមធ្យម សម្រាប់វិនិយោគសាធារណៈ ជំពូក ២១ ត្រូវបានរៀបចំ និងបញ្ជូនទៅ អគ្គ.នាយកដ្ឋានគោលនយោបាយ

២. ក្រុមការងារ FMIS របស់ GDNT បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងដោះស្រាយបញ្ហានានាជាមួយអង្គភាពពាក់ព័ន្ធនឹងការងារ FMIS ដូចជា FMIS Contructor & នាយកដ្ឋានព័ត៌មានវិទ្យា អគ្គ.ថវិកា និង អគ្គ. ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

៣. ការពិនិត្យ និងកែលម្អកិច្ចបញ្ជិកាគណនេយ្យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យស្របទៅនឹងប្លង់គណនេយ្យថ្មីត្រូវបានពង្រឹង, ណែនាំមន្ត្រីជំនាញថ្នាក់កណ្តាល និងថ្នាក់រាជធានីខេត្តក្នុងការប្រើប្រាស់ប្លង់គណនេយ្យឱ្យបានត្រឹម ជាពិសេសការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ FMIS បន្តបញ្ចូលប្រតិបត្តិការទៅក្នុងប្រព័ន្ធ FMIS ស្របតាមគណនីនៅក្នុងប្រព័ន្ធ FMIS ដែលស្នើឡើងដោយ Contractor។

<u>**វិងសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷**</u>

១. (២២.៥.១.)របចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធ FMIS ត្រូវបានរៀបចំកែសម្រួល និងអនុម័តជាផ្លូវការ ជាមួយយន្តការលើកទឹកចិត្តសមស្របជាលក្ខណៈប្រព័ន្ធរចនាសម្ព័ន្ធក្រុមការងារគ្រប់គ្រងគម្រោង FMIS **៥០%**

២.(២២.៥.៤.)ឯកសារផែនការពង្រីកការអនុវត្តប្រព័ន្ធ FMIS ជំហានទី២ ត្រូវបានកសាងចប់ជាស្ថាពរឡើងនៅខែឧសភា ឆ្នាំ២០១៦ និងមានសេចក្តីព្រាងផែនការពង្រីកការអនុវត្តប្រព័ន្ធ FMIS ជំហានទី២ **៨៥%**

៣.(២២.៥.៩.)អ្នកប្រើប្រាស់និងសិទ្ធិប្រើប្រាស់ប្រព័ន្ធ FMIS ជំហានទី២ ដំណាក់កាលទី១ត្រូវបានកំណត់ **៦០%**។

**៣.២.៣.គោលបំណង២៣÷ ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និង ប្រព័ន្ធតម្លាភាព (៧៦%)**

ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និង ប្រព័ន្ធតម្លាភាព ពិតណាស់នឹងត្រូវផ្តោតលើការដាក់ឱ្យអនុវត្តថវិកាកម្មវិធីទូលំទូលាយ ស្របពេលដែលការរៀបចំស្តង់ដារគណនេយ្យសាធារណៈស្របតាមស្តង់ដារ IPSAS, គណនីបង្គរ, ការពង្រីកការប្រើប្រាស់ FMIS, ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ប្រកបដោយសុក្រឹតភាពនិងសមានគតិភាព ជាពិសេស ការកែលម្អទម្រង់របាយការណ៍ និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន។

ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ៧៦% និងមានចង្កោមសកម្មភាពចំនួន ៤ អនុវត្តដោយ អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គលេខាធិការដ្ឋាន កសហវ និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ក្នុងនោះ ចង្កោមសកម្មភាព ២៣.១ រៀបចំស្តង់ដារគណនេយ្យសាធារណៈស្របតាមស្តង់ដារ IPSAS និងដាក់ឱ្យអនុវត្តជាបណ្តើរៗតាមលំដាប់លំដោយព្រមទាំងផ្សារភ្ជាប់ទៅនឹងការពង្រីកការប្រើប្រាស់ FMIS និងបង្កើតជម្រើសសម្រាប់ការអនុវត្ត ជាជំហានៗទៅរកការអនុវត្តគណនីបង្គរ ៦៨%, ២៣.២ ការកែលម្អទម្រង់របាយការណ៍អនុវត្តថវិកាដែលត្រូវផ្ញើទៅគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិ ៨៤%, ២៣.៣ ការកែលម្អទម្រង់របាយការណ៍ និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន ៩៦%, និង ២៣.៤ ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ៥៥%។

<u>**ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷**</u>

១. របាយការណ៍ Flash report (Socio-Economic Trends) និង ព្រឹត្តិប័ត្រស្ថិតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានចេញផ្សាយទាំងភាសាខ្មែរនិងអង់គ្លេស

២. របាយការណ៍អនុវត្តថវិកាឆមាសទី១ ត្រូវបានរៀបចំ និងផ្សព្វផ្សាយតាមរយៈគេហទំព័រ កសហវ និងគ្រោងចុះផ្សាយនៅគេហ៍ទំព័រ កសហវ នៅដើមត្រីមាសទី៣

៣. សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកម្រិតអន្តរអគ្គ.ដ្ឋាន។

**<u>វិងសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷</u>**

១. (២៣.១.៤.)ជំរុញការប្រាក់ត្រូវទារ និងត្រូវសង ឱ្យមានការកត់ត្រាក្នុងកិច្ចបញ្ជិកាគណនេយ្យ ដើម្បីសិក្សា និងបង្កើតឱ្យមានជម្រើសដើម្បីឈានទៅរកគណនេយ្យបង្គរជាជំហ៊ានៗ ត្រូវបាន អនុវត្ត **៥០%**

២.(២៣.២.៣.)សេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ ត្រូវបានប្រជុំកែសម្រួល និងរៀបចំដាក់ ជូនគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិ **៥០%**

៣.(២៣.៤.៥.)លិខិតបទដ្ឋានគតិយុត្តការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានពិនិត្យ និងរៀបចំកែ សម្រួល **២០%**

៤. (២៣.៤.៦.)មតិប្រឹក្សាច្បាប់លើលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការដាក់ឱ្យអនុវត្តយន្តការដើម្បី បញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវបានផ្តល់ជូនតាមផែនការ **៩០%**។

**៣.២.៤.គោលបំណង២៤÷ ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និង គណនេយ្យភាព (ប្រព័ន្ធត្រួតពិនិត្យ) (៧៧%)**

ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព គឺផ្តោត ចាំបាច់ចំពោះភាពទទួលខុសត្រូវលើវិធានការលើកទឹកចិត្ត និងរឹតត្បិតចំពោះកំហុសឆ្គង ឬ ការគ្រប់គ្រង ធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព ជាពិសេសការបង្កើន គណនេយ្យភាពនូវការអនុវត្តយន្ត ការត្រួតពិនិត្យ។

ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ៧៧% និងចង្កោមសកម្មភាពចំនួន ០៤ អនុវត្តដោយ អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គ-លេខាធិការដ្ឋាន កសហវ ក្នុងនោះ ចង្កោមសកម្មភាព ២៤.១ បង្កើតឱ្យមានទណ្ឌកម្មរដ្ឋបាលសមស្របចំពោះ កំហុសឆ្គង ឬការគ្រប់គ្រងធនធានសាធារណៈមិនសមស្របនិងគ្មានប្រសិទ្ធភាព ហើយទណ្ឌកម្មនេះត្រូវចែង ក្នុងលិខិតបទដ្ឋានគតិយុត្ត និងធ្វើការផ្សព្វផ្សាយ និងណែនាំឱ្យបានទូលំទូលាយ ៤០%, ២៤.២ ធ្វើបច្ចុប្បន្នភាព និងផ្តល់សិទ្ធិអំណាច និងភាពទន់ភ្លន់ជាបន្តបន្ទាប់ជូនអង្គភាពថវិកា ១០០%, ២៤.៤ រៀបចំ និងដាក់ឱ្យអនុវត្ត ទម្រង់របាយការណ៍វឌ្ឍនភាពអនុវត្តថវិកាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ (ដោយរំលេចពីការរៀបចំថវិកា, លទ្ធផលសម្រេចបាន និងវិធានការដោះស្រាយ ពីក្រសួង ស្ថាប័ន ទៅ កសហវ និងនៅផ្ទៃក្នុងក្រសួងនីមួយៗ) ៧៦%។ ដោយឡែក ២៤.៣ ត្រួតពិនិត្យឡើងវិញលើការអនុវត្តសិទ្ធិអំណាចនិងភាពទន់ភ្លន់ដែលបានផ្តល់ជូន ដើម្បីធ្វើជាមូលដ្ឋានក្នុងការពង្រីកការផ្តល់សិទ្ធិអំណាច និងភាពទន់ភ្លន់មិនមានសកម្មភាពគ្រោងអនុវត្តក្នុងត្រី មាសទី ២ នេះទេ។

**<u>ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷</u>**

១. អង្គភាពថវិកាសម្រាប់បន្តអនុវត្ត ឆ្នាំ២០១៦ ត្រូវបានពង្រឹងនិងកែលម្អការរៀបចំបង្កើត; ពង្រីក បន្ថែមនូវការដាក់ឱ្យអនុវត្ត អង្គភាពថវិកាថ្មីនៅឆ្នាំ២០១៦ របស់ក្រសួងស្ថាប័ន; ការស្នើសុំបង្កើត

អង្គភាពថវិការបស់ ក្រសួង ស្ថាប័ន ដែលបាននឹងកំពុងអនុវត្តថវិកាកម្មវិធីបានពិនិត្យនិងកែសម្រួល

២. បានពិនិត្យនិងកែសម្រួលលើការផ្តល់សិទ្ធិប្រើប្រាស់រជ្ជទេយ្យបុរេប្រទានក្នុងការទិញផ្ទាល់ពីក្រុមហ៊ុន; បានពិនិត្យនិងកែសម្រួលលើសិទ្ធិមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ; បានពិនិត្យនិងផ្តល់សិទ្ធិក្នុងការកែសម្រួល ក្រុមការងារលទ្ធកម្ម; កែសម្រួលនិងរៀបចំគោលការណ៍និង នីតិវិធីផ្ទេរក្នុងបន្ទែមសម្រាប់អនុវត្តថវិកា; បានពិនិត្យនិងកែសម្រួលសិទ្ធិចាត់ចែងការអនុវត្តថវិការបស់ខ្លួន

៣. សំណើថវិកាកម្មវិធីប្រចាំត្រីមាសត្រូវបានកែលម្អទម្រង់

៤. ទម្រង់របាយការណ៍នៃការធ្វើនិយ័តកម្មត្រូវបានកែលម្អទម្រង់

៥. ទម្រង់របាយការណ៍វឌ្ឍនភាពថវិកាប្រចាំត្រីមាសនិង/ឬឆមាសនិងប្រចាំឆ្នាំត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត (ចាប់ផ្តើមអនុវត្តចាប់ពីត្រីមាសទី ១ ឆ្នាំ២០១៦)។

**<u>រីឯសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷</u>**

១. (២៤.១.៣.) លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិធានការរួមនៃការដាក់ទណ្ឌកម្មរដ្ឋបាលក្នុងវិស័យហិរញ្ញវត្ថុ សាធារណៈត្រូវបានប្រមូលនិងចងក្រង 0%

២. (២៤.២.៧.) ប្រកាសស្តីពីក្របខ័ណ្ឌសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អង្គភាពថវិកា កសហវ ត្រូវផ្សព្វ ផ្សាយនិងដាក់អនុវត្ត 0%

៣. (២៤.៤.៥.) សេចក្តីព្រាងលើកទី១ របាយការណ៍វឌ្ឍនភាព អនុវត្តថវិកាជំពូក២១ (វិនិយោគផ្ទាល់) និងជំពូក៦១ (ជួសជុលនិងថែទាំផ្លូវថ្នល់ ធារាសាស្ត្រ) ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំត្រូវបានរៀបចំ 0%។

## ៣.៣. ផ្នែកទី៣÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (៨៧%)

ការរៀបចំថវិកាផ្សារភ្ជាប់ទៅនឹងគោលគោលនយោយ គឺជាជំហានដ៏សំខាន់សម្រាប់ការអនុត្តក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ នេះ។ ការអនុវត្តថវិកាកម្មវិធីប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺទាមទារឱ្យក្រសួង-ស្ថាប័ន កំណត់នូវចក្ខុវិស័យ គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធីឱ្យច្បាស់លាស់ និងសង្គតិភាពជាមួយយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំក្របខណ្ឌថវិការយៈពេលមធ្យម ដើម្បីកំណត់ពិដានថវិកាសម្រាប់វិស័យ និងឈានទៅការរៀបចំពិដានសម្រាប់ក្រសួង-ស្ថាប័ន។

សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៦ ផ្នែកទី៣÷ ការផ្សាភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (សម្រេចបាន ៨៧%) ដោយមានគោលបំណងចំនួន ៦ រួមមាន (១) ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី, (២) ការរៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា, (៣) ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព (រវាងនីតិបញ្ញត្តិនិងនីតិប្រតិបត្តិ, រវាងកសហវនិងក្រសួង-ស្ថាប័ន និងនៅក្នុងក្រសួង-ស្ថាប័ន), (៤) ការពង្រឹងការរៀបចំគោលនយោបាយ និងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ (ការរៀបចំគោលនយោបាយនិងផែនការចំណូលនិងចំណាយរយៈពេលមធ្យម), (៥) ការរៀបចំប្រព័ន្ធត្រួតពិនិត្យ និង (៦) ការពង្រឹងការអនុវត្តគោល

នយោបាយវិមជ្ឈការហិរញ្ញវត្ថុ និងចង្កោមសកម្មភាពចំនួន ២៣ និងត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានចំនួន ០៧ រួមមាន អគ្គលេខាធិការដ្ឋាន គសហវ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋាន។

**៣.៣.១. គោលបំណង៣១÷ ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី (១០០%)**

ការអនុវត្តថវិកាកម្មវិធីជាឧបករណ៍ជំរុញឱ្យការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ បម្រើឱ្យយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។ ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ១០០% និងមានចង្កោមសកម្មភាពចំនួន ៣ អនុវត្តដោយអគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គលេខាធិការដ្ឋាន គសហវ ក្នុងនោះ ចង្កោមសកម្មភាព ៣១.១ ការពិនិត្យឡើងវិញនិងការកែលម្អការអនុវត្តថវិកាកម្មវិធី ១០០%, ៣១.២ ការរៀបចំយុទ្ធសាស្ត្រដើម្បីពង្រីកថវិកាកម្មវិធី ១០០% និង ៣១.៣ ការអនុវត្តផែនការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពសម្រាប់ការពង្រឹងនិងពង្រីកការអនុវត្តថវិកាកម្មវិធី ១០០%។

**<u>ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷</u>**

១. ឯកសារវាយតម្លៃអំពីការរៀបចំ និងអនុវត្តថវិកាកម្មវិធី របស់ក្រសួងអនុវត្តថវិកាកម្មវិធីត្រូវបានរៀបចំ
២. ការអនុវត្តថវិកាកម្មវិធីនៅតាម ក្រសួង-ស្ថាប័ន អនុវត្តថវិកាកម្មវិធីត្រូវបានចុះពិនិត្យ និងពង្រឹង
៣. គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីដល់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី (ថ្នាក់កណ្តាល និងមន្ទីរជំនាញ) ត្រូវបានផ្សព្វផ្សាយ
៤. គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធីដល់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី (ថ្នាក់កណ្តាល និងមន្ទីរជំនាញ) ត្រូវបានផ្សព្វផ្សាយ
៥. គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកា (សិទ្ធិអំណាចនៃការធ្វើនិយ័តកម្ម) ត្រូវបានពិនិត្យ និងកែលម្អឡើងវិញដើម្បីឱ្យស្របតាមស្ថានភាពជាក់ស្តែង
៦. យុទ្ធសាស្ត្រ ដើម្បីពង្រីកថវិកាកម្មវិធីត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។

**៣.៣.២. គោលបំណង៣២÷ ការរៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា (១០០%)**

ការរៀបចំថវិកាគ្រប់ជ្រុងជ្រោយ សំដៅដល់ថវិកាពេញលេញដែលឆ្លុះបញ្ចាំងគ្រប់ប្រភពចំណូល និងគ្រប់មុខសញ្ញា។ ជាក់ស្តែង គោលបំណងនេះជារួម សម្រេចបាន ១០០% និងមានចង្កោមសកម្មភាពចំនួន ២ អនុវត្តដោយអគ្គនាយកដ្ឋានថវិកា ក្នុងនោះ ចង្កោមសកម្មភាព ៣២.១ បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្តនិងថវិកាមូលធន តាមរយៈក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF), ផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាកម្មវិធី (PB) ១០០% និង ៣២.២ ការបញ្ចូលចំណូល-ចំណាយដែលនៅក្រៅបរិបទថវិកាទៅក្នុងថវិកាប្រចាំឆ្នាំ ដោយរួមទាំងថវិកាដៃគូអភិវឌ្ឍន៍ មិនមានសកម្មភាពអនុវត្តក្នុងត្រីមាសទី២នេះទេ។

**<u>ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷</u>**

១. ក្របខ័ណ្ឌចំណាយរយៈខ្លី និងមធ្យមនៃចំណាយវិនិយោគសាធារណៈ (ជំពូក២១) និងចំណាយជួសជុលនិងថែទាំ (ជំពូក៦១) ត្រូវបានរៀបចំបញ្ចូលក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រថវិកា (BSP) (ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច) បានបញ្ចូលក្របខណ្ឌចំណាយវិនិយោគ និងចំណាយជួសជុលថែទាំ ទៅក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៧-២០១៩ (១០០% ក្នុងត្រីមាសទី១)។

**៣.៣.៣.គោលបំណង៣៣÷ ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព (១០០%)**

នៅពេលថវិកាកម្មវិធីត្រូវបានដាក់ឲ្យអនុវត្តយ៉ាងទូលំទូលាយ ហើយអង្គភាពថវិកាត្រូវបានធ្វើវិមជ្ឈការអំណាច និងការទទួលខុសត្រូវ ប្រព័ន្ធបន្ទាត់គណនេយ្យភាព គួរត្រូវបានកំណត់ឱ្យបានច្បាស់លាស់រវាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ រវាង កសហវ និងក្រសួង-ស្ថាប័ន និងផ្ទៃក្នុងក្រសួង-ស្ថាប័ន។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នអនុវត្តថវិកាកម្មវិធី ត្រូវបែងចែកការទទួលខុសត្រូវឱ្យបានច្បាស់លាស់ស្របតាមគោលការណ៍នៃការរៀបចំ និងអនុវត្តថវិកាកម្មវិធី។ ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ១០០% និងមានចង្កោមសកម្មភាពចំនួន ០៤ អនុវត្តដោយអគ្គនាយដ្ឋានថវិកា ក្នុងនោះ ចង្កោមសកម្មភាព ៣៣.១ ការពិនិត្យឡើងវិញនិងរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល ក្នុងបរិបថនៃការអនុវត្តថវិកាកម្មវិធី ១០០% និង៣៣.៤ ការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន ឱ្យឆ្លើយតបទៅនឹងប្រព័ន្ធដំណើរការការងារថ្មីដែលត្រូវបានបង្កើត ១០០%។ ដោយឡែក សម្រាប់ចង្កោមសកម្មភាព ៣៣.២ និង ៣៣.៣ មិនមានសកម្មភាពគ្រោងអនុវត្តដោយអគ្គនាយកដ្ឋានក្នុងត្រីមាសទី២ នេះទេ។

**<u>ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷</u>**

១. ប្រកាសលេខ ២៧៤ សហវ.ហក ចុះថ្ងៃទី១៧ ខែមីនាឆ្នាំ២០១៦ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុ ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមផ្ទាល់តាម ក្រសួង-ស្ថាប័ន នៅរដ្ឋបាលកណ្តាលក្នុងការពិនិត្យសម្រេចផ្តល់ទិដ្ឋាការលើលិខិតធានាចំណាយ និងលើអាណត្តិបើកប្រាក់ត្រូវបានដាក់ឱ្យប្រើ។

**៣.៣.៤.គោលបំណង៣៤÷ ការពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ(៥៩%)**

ការរៀបចំគោលនយោបាយ និងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ គឺទាមទារឱ្យមានសមត្ថភាពវិភាគបរិបទក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងសមត្ថភាពការរៀបចំក្របខណ្ឌថវិការយៈពេលមធ្យម ដើម្បីជាមូលដ្ឋានសម្រាប់ក្របខណ្ឌចំណូល-ចំណាយរយៈពេលមធ្យម និងពិដានសម្រាប់តាមវិស័យ ឬ ក្រសួង ស្ថាប័ន។ ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ៥៩% និងមានចង្កោមសកម្មភាពចំនួន ៣ អនុវត្តដោយអគ្គ-នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ក្នុងនោះ ចង្កោមសកម្មភាព ៣៤.១.ពង្រឹងសមត្ថភាពរៀបចំនិងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច មិនមានសកម្មភាពអនុវត្តក្នុងត្រីមានទី២ នេះទេ, ៣៤.២.ពង្រឹងសមត្ថភាពរៀបចំនិងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ២៥% និង ៣៤.៣. ពង្រឹងសមត្ថភាពវិភាគ និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៦៣%។

<u>ជាក់ស្តែងសូចនាករមិនសម្រេចបានតាមគោលដៅ គឺ៖</u>

១. (៣៤.២.១.) សិក្ខាសាលាពិគ្រោះយោបល់ និងបញ្ច្រាបពីដំណើរការក្នុងការរៀបចំ MTEF ២០១៨-២០២០ ត្រូវបានរៀបចំដល់ក្រសួងស្ថាប័នពាក់ព័ន្ធនានា **0%**

២. (៣៤.៣.៥.) សិក្ខាសាលាផ្សព្វផ្សាយ GFS &TOFE និង ពង្រឹងការប្រមូលទិន្នន័យពីស្ថាបនាពាក់ព័ន្ធថ្នាក់ជាតិ និងក្រោមជាតិ (ក្នុង១ឆ្នាំ១ដង លើកលែងឆ្នាំទី៣) ត្រូវបានរៀបចំ **៥0%**

៣.(៣៤.៣.៦.) របាយការណ៍ពិភាក្សា និងពិនិត្យផ្ទាល់នៅថ្នាក់មូលដ្ឋាន ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិភាគក្រោយការតាមដានប្រចាំត្រីមាសលើស្ថានភាពសេដ្ឋកិច្ចជារួម ត្រូវបានរៀបចំ **៦0%**

៤. (៣៤.៣.៩.) កិច្ចពិភាក្សា និងពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងកែសម្រួលគោលនយោបាយពន្ធ ត្រូវបានធ្វើឡើង **៥0%**

៥. (៣៤.៣.១២.) មុខទំនិញដែលចាំបាច់ក្នុងចំណោមទំនិញអាទិភាព ដែលទាមទារឱ្យមានការសិក្សាលើការកែសម្រួលអត្រាពន្ធគយ ត្រូវបានកំណត់ **៦0%**។

**៣.៣.៥. គោលបំណង៣៥៖ ការរៀបចំប្រព័ន្ធត្រួតពិនិត្យ (៨៦%)**

ទន្ទឹមនឹងការអនុវត្តថវិកាកម្មវិធីពេញលេញ ការរៀបចំប្រព័ន្ធត្រួតពិនិត្យកាន់តែមានមុខងារសំខាន់សម្រាប់ការអនុវត្តថវិកាឱ្យមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងសន្សំសំចៃ។ ការបែងចែកតួនាទីរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច គួរត្រូវបានរៀបចំឱ្យបានច្បាស់លាស់ ដើម្បីបញ្ចៀសការធ្វើការងារត្រួតគ្នានៅតាមក្រសួង-ស្ថាប័ន។ ទន្ទឹមនេះ សវនកម្មផ្ទៃងក្នុង ក៏ត្រូវបានបង្កើតឡើងដើម្បីបង្កើនតម្លៃបន្ថែម និងកែលម្អដំណើរក្នុងអង្គភាព។ សវនកម្មផ្ទៃក្នុង នឹងជួយអង្គភាពសម្រេចបាននូវគោលបំណង ដោយនាំមកជាប្រព័ន្ធ វិន័យដើម្បីវាយតម្លៃ និងកែលម្អនូវប្រសិទ្ធភាពនៃការគ្រប់គ្រង, ការត្រួតពិនិត្យ និងដំណើការអភិបាលកិច្ចនៅក្នុងអង្គភាព។ ការត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការរៀបចំ និងចាត់ចែង ដើម្បីធានាឱ្យសម្រេចបាននូវគោលបំណង (១) ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពកិច្ចដំណើការរបស់អង្គភាព, (២) ភាពជឿទុកចិត្តលើរបាយការណ៍ហិរញ្ញវត្ថុនិង (៣) អនុលោមតាមច្បាប់និងបទបញ្ញត្តិជាធរមាន។

ជាក់ស្តែង គោលបំណងនេះជារួម សម្រេចបាន ៨៦% និងមានចង្កោមសកម្មភាពចំនួន ៥ អនុវត្តដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គាធិការដ្ឋាន និងលេខាធិការដ្ឋាន កសហវ ក្នុងនោះ ចង្កោមសកម្មភាព ៣៥.១ ត្រួតពិនិត្យមើលឡើងវិញពីប្រព័ន្ធត្រួតពិនិត្យ អធិការកិច្ច សវនកម្ម និងសវនកម្មផ្ទៃក្នុងនាពេលបច្ចុប្បន្ននៅគ្រប់ក្រសួង-ស្ថាប័ន ១០០%, ៣៥.២ រៀបចំប្រព័ន្ធត្រួតពិនិត្យថ្មីឱ្យមាន ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងឆ្លើយតបបានទៅនឹងបរិបទថ្មី ដើម្បីបំពេញមុខងារគ្នាទៅវិញទៅមក សម្រាប់ការគ្រប់គ្រងក្រសួង-ស្ថាប័ន ៨៤%, ៣៥.៣ កែលម្អយន្តការត្រួតពិនិត្យ ដើម្បីធានាការឆ្លើយតបក្នុងការបំពេញមុខងាររវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ចប្រកបដោយប្រសិទ្ធភាពទៅនឹងលទ្ធផល ដែលរកឃើញដោយសវនកម្មផ្ទៃក្នុង និងអធិការកិច្ច សម្រេចបាន ៦១%, ៣៥.៤ រៀបចំនិងកែលម្អ ផែនការសកម្មភាព និងកម្មវិធីសវនកម្ម/អធិការកិច្ច ប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងចាត់វិធានការវាយតម្លៃហានិភ័យ ដែលផ្តល់

អនុសាសន៍ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៧៨%។ ដោយឡែក ចង្កោមសកម្មភាព ៣៥.៥ មិនមានផែនការអនុវត្តដែលគ្រោងដោយអគ្គនាយកដ្ឋានពាក់ព័ន្ធ។

**ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷**

១. នីតិវិធីនៃការកំណត់គោលបំណង និងវិសាលភាពសវនកម្ម និងការស្វែងយល់សវនដ្ឋាននៃដំណាក់កាលផែនការចុះសវនកម្ម ត្រូវបានរៀបចំ

២. សេចក្តីព្រាងនីតិវិធីនៃការវាយតម្លៃហានិភ័យក្នុងដំណើរការ (Assess risks in the process) និងការកំណត់កុងត្រូលខ្វះចន្លោះ (Control gap) ត្រូវបានរៀបចំពិនិត្យកែលម្អរួច

៣. សវនដ្ឋានចំនួន ៥ គោលដៅ ត្រូវបានជំរុញនិងកែលម្អតាមអនុសាសន៍សវនករចុះតាមដានអនុសាសន៍ នៅថ្នាក់កណ្តាល និងខេត្ត និងចេញលិខិតជម្រុញអនុវត្តអនុសាសន៍ចុះតាមដានការអនុវត្តអនុសាសន៍សវនកម្ម

៤. សេចក្តីព្រាងយន្តការធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ជាតិ ត្រូវបានដាក់ឆ្លងយោបល់នៅកម្រិតនាយកដ្ឋានអធិការកិច្ចរដ្ឋបាលថ្នាក់ជាតិ

៥. ផែនការសវនកម្មក្រសួងស្ថាប័នសរុបចំនួន ៥គោលដៅត្រូវបានពិនិត្យនិងផ្តល់យោបល់កែលម្អ។

**រីឯសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷**

១. (៣៥.២.១.)មតិប្រឹក្សាច្បាប់លើការកែលម្អ យន្តការត្រួតពិនិត្យដើម្បីធានាការឆ្លើយតបក្នុងការបំពេញមុខងាររវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ប្រកបដោយប្រសិទ្ធភាពទៅនឹងលទ្ធផលដែលរកឃើញដោយសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចគ្រប់គ្រង គ្រប់ក្រសួងស្ថាប័ន ត្រូវបានផ្តល់ជូនតាមផែនការ 0%

២. (៣៥.៣.៦.)សេចក្តីព្រាងយន្តការធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឆ្លងយោប-ល់នៅកម្រិតនាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ក្នុងនោះមាតិកានៃសេចក្តីព្រាងយន្តការធ្វើអធិការកិច្ចហិរញ្ញវត្ថុរួមមាន ការគ្រប់គ្រងសាច់ប្រាក់ប្រត្តិបត្តិការចំណូល (សារពើពន្ធ និងមិនមែនសារពើពន្ធ) ប្រតិបត្តិការចំណាយ ការគ្រប់គ្រងលទ្ធកម្ម ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងសមតុល្យ ៧0%។

**៣.៣.៦. គោលបំណង៣៦÷ ការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ (៨២%)**

ការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ សំដៅគោលនយោបាយផ្ទេរផ្នែកហិរញ្ញវត្ថុពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ដើម្បីធានាដល់អភិវឌ្ឍន៍ថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ លក្ខណៈភូមិសាស្រ្ត, សេដ្ឋកិច្ច-សង្គម និងប្រជាសាស្រ្ត គឺខុសគ្នានៅថ្នាក់ក្រោមជាតិ ដូចនេះ ទំហំហិរញ្ញវត្ថុគាំទ្រគឺខុសតំបន់មួយទៅតំបន់មួយ។ ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ៨២% និងមានចង្កោមសកម្មភាពចំនួន ៦ អនុវត្តដោយអគ្គនាយដ្ឋានរដ្ឋបាលហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋាន ក្នុងនោះចង្កោមសកម្មភាព ៣៦.១. ពិនិត្យមើលឡើងវិញ និងអនុវត្តគោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យមនិងវែង ៥៧%, ៣៦.២ អនុវត្តការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ១០០%, ៣៦.៣.

អនុវត្តសាកល្បងនិងពង្រីកមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) ៧៦%, ៣៦.៤. ពិនិត្យមើលឡើងវិញ និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្រ្តថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ១០០%, ៣៦.៥. រៀបចំនិងអនុវត្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ ៨០%, ៣៦.៦. រៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំនិងការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាសម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ៨៣%។

**<u>ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ៖</u>**

១. លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានា (អនុក្រឹត្យ/ប្រកាស) ដើម្បីអនុវត្តការប្រមូលចំណូលផ្ទាល់ (ចែករំលែក) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ប្រជុំពិភាក្សា

២. គោលការណ៍ណែនាំស្តីពី ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

៣.(៣៦.១.៥.)គោលការណ៍កំណត់លក្ខណៈវិនិច្ឆ័យ ត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត និងរដ្ឋបាលខេត្ត ចំនួន ០៦ ត្រូវបានជ្រើសរើសសម្រាប់អនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកានៅឆ្នាំ ២០១៧។

**<u>រីឯសូចនាករមិនសម្រេចបានតាមគោលដៅ គឺ៖</u>**

១. (៣៦.១.១.)សេចក្តីព្រាងឯកសារគោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យម និងវែងត្រូវបានដាក់ប្រជុំពិភាក្សាប្រមូលធាតុចូល **៧០%**

២. (៣៦.១.៣.)សេចក្តីព្រាងសៀវភៅណែនាំស្តីពី ការរៀបចំនិងអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបញ្ចប់ និង ដាក់ឱ្យប្រើប្រាស់ **៥០%**

៣.(៣៦.១.៥.)សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំសង្កាត់ត្រូវបានដាក់ពិភាក្សាក្នុងកម្រិត កសហវ **៥០%**

៤. (៣៦.៣.១.)លិខិតបទដ្ឋានគតិយុត្តិស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមប្រឹក្សាគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់ឱ្យប្រើប្រាស់ **៩០%**

៥. (៣៦.៣.៣.)សេចក្តីព្រាងបែបបទ និងនីតិវិធីនានាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំនិងដាក់សំណើគម្រោងដើម្បីស្នើសុំមូលនិធិ SNIF **៦០%**

៦. (៣៦.៣.៤.)សេចក្តីព្រាងសៀវភៅណែនាំស្តីពីប្រតិបត្តិការគម្រោងមូលនិធិ SNIF ត្រូវបានដាក់ប្រជុំពិភាក្សា **៨០%**

៧. (៣៦.៥.១.)របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃឡើងវិញនូវការអនុវត្តសាកល្បងយន្តការផ្ទេរធនធានរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ ត្រូវបានដាក់ប្រជុំពិភាក្សាអ្នកពាក់ព័ន្ធនិងដាក់ជូនថ្នាក់ដឹកនាំពិនិត្យផ្តល់អនុសាសន៍ណែនាំ **៨០%**

៨. (៣៦.៥.២.)លិខិតបទដ្ឋានគតិយុត្តស្តីពី ការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌត្រូវបានដាក់ប្រជុំពិភាក្សាអង្គភាពពាក់ព័ន្ធសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ ត្រូវបានដាក់ប្រជុំពិភាក្សា **៨០%**

៩. (៣៦.៦.១.)នីតិវិធីនិងគោលការណ៍សម្រាប់រៀបចំ និងអនុវត្តថវិកាកម្មវិធី និង អង្គភាពថវិកាសម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់ឱ្យប្រើប្រាស់ **៧៥%**។

## ៣.៤. ផ្នែកទី៤÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ (៧៦%)

គណនេយ្យភាពលើសមិទ្ធកម្ម គឺសំដៅដល់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិនិងបុគ្គលចំពោះមុខងារ និងភារកិច្ចដែលបានអនុវត្តតាមរយៈប្រព័ន្ធរបាយការណ៍។ សមាសធាតុទំនាក់ទំនងសំខាន់ពង្រឹងគណនេយ្យភាព គឺ (១) ដាក់ចេញគោលបំណងដែលអាចវាស់វែងបាន និងការទទួលខុសត្រូវច្បាស់លាស់ (២) រៀបចំផែនការដើម្បីសម្រេចឱ្យបាននូវគោលបំណង (៣) អនុវត្តសកម្មភាព និងធ្វើការត្រួតពិនិត្យតាមវឌ្ឍនភាព (៤) រាយការណ៍វឌ្ឍនភាព និង (៥) វាយតម្លៃលទ្ធផល និងផ្តល់មតិយោបល់ត្រលប់មកវិញ។

ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ គឺមានគោលដៅជាក់លាក់នូវការចង់បាន ក្របខ័ណ្ឌថវិកា ក្របខ័ណ្ឌគណនេយ្យភាព និងក្របខ័ណ្ឌសវនកម្មដោយផ្អែកលើសមិទ្ធកម្មដែលផ្សារភ្ជាប់ការចំណាយសម្រាប់កម្មវិធីនីមួយៗ។ ទន្ទឹមនេះ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ មានគោលបំណងចំនួន៤ រួមមាន (១) បង្កើតក្របខ័ណ្ឌថវិកាដោយផ្អែកលើសមិទ្ធកម្ម (២) បង្កើតក្របខណ្ឌគណនេយ្យភាពនៃសមិទ្ធិកម្ម (៣) បង្កើតក្របខណ្ឌសវនកម្មលើសមិទ្ធិកម្ម និង (៤) រៀបចំផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និងអជ្ញាធរសវនកម្មជាតិ)។

សម្រាប់ត្រីមាសទី២នេះ ផ្នែកទី៤÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ (សម្រេចបាន ៧៦%) ត្រូវបានបន្តអនុវត្ត ដោយកំណត់ចេញជា ៤គោលបំណង និងចង្កោមសកម្មភាពចំនួន ០៩ អនុវត្តដោយ អគ្គនាយកដ្ឋានថវិកា, អគ្គលេខាធិការដ្ឋាន កសហវ និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៣.៤.១. គោលបំណង៤១ ÷ បង្កើតក្របខ័ណ្ឌថវិកាដោយផ្អែកលើសមិទ្ធកម្ម (៨១%)

ការបង្កើតក្របខ័ណ្ឌថវិកាដោយផ្អែកលើសមិទ្ធកម្ម គឺដើម្បីពង្រឹង និងលើកកម្ពស់សមត្ថភាពអនុវត្តថវិកាតាមផែនការឱ្យស្របតាមក្របខ័ណ្ឌគតិយុត្ត ដែលតម្រូវឱ្យគោរពវិធានថវិកា និងនីតិវិធីដែលបានកំណត់លើសពីនេះគឺមានប្រព័ន្ធគ្រប់គ្រងដែលអាចវាយតម្លៃនិងរក្សាបាននូវសមិទ្ធកម្ម។ ជាក់ស្តែង គោលបំណងនេះសម្រេចបាន ៨១% និងមានចង្កោមសកម្មភាពចំនួន ២ ដែលអនុវត្តដោយ អគ្គនាយកដ្ឋានថវិកា និងអគ្គលេខាធិការដ្ឋាន កសហវ ក្នុងនោះ ចង្កោមសកម្មភាព ៤១.១ សិក្សា និងរៀបចំក្របខ័ណ្ឌគោលនៃគោលការណ៍ថវិកាផ្អែកលើសមិទ្ធកម្ម (Performance Based Budgeting PBB) សម្រេចបាន ៧៣% និង ៤១.២ ពិគ្រោះយោបល់លើគោលការណ៍ថវិការផ្អែកលើសមិទ្ធកម្ម (មិនទាន់ដល់ពេលអនុវត្តក្នុងត្រីមាសទី២)។

**<u>ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ÷</u>**

១. ក្របខណ្ឌគតិយុត្តពាក់ព័ន្ធសម្រាប់ជាមូលដ្ឋាននៃការអនុម័តថវិកាកម្មវិធី និងថវិកាផ្អែកលើសមិទ្ធកម្មត្រូវបានសិក្សា និងចងក្រងសម្រាប់ជាមូលដ្ឋាននៃការអនុម័តថវិកាតាមកម្មវិធី និងថវិកាផ្អែកលើសមិទ្ធកម្ម

២. ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមន្ត្រីរាជការ កសហវ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ។

**រីឯសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷**

១. (៤១.១.៦.) ប្រកាសស្តីពីវិធាននិងនីតិវិធីនៃការរៀបចំការអនុវត្តការត្រួតពិនិត្យ និងវាយតម្លៃនៃការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៃ កសហវ ត្រូវបានរៀបចំ **២០%**។

### ៣.៤.២. គោលបំណង៤២÷ បង្កើតក្របខណ្ឌគណនេយ្យភាពនៃសមិទ្ធកម្ម

ការបង្កើតក្របខណ្ឌគណនេយ្យភាពនៃសមិទ្ធកម្ម គឺដើម្បីលើកកម្ពស់សមិទ្ធកម្មមន្ត្រី និងគ្រប់គ្រងសមិទ្ធកម្មមន្ត្រី ប្រកបដោយ គុណភាព និងប្រសិទ្ធភាព។

ការបង្កើតក្របខណ្ឌគណនេយ្យភាពនៃសមិទ្ធិកម្ម គឺដើម្បីលើកកម្ពស់សមិទ្ធកម្មមន្ត្រី និងរៀបចំប្រព័ន្ធមួយច្បាស់លាស់ ដែលអាចវាយតម្លៃនិងរក្សាបាននូវសមិទ្ធកម្មនៃការអនុវត្តការងារទាំងការងារកែទម្រង់ និងមិនកែទម្រង់។ ជាក់ស្តែង គោលបំណងនេះ មិនទាន់អាចវាស់វែងបានទេ ដោយហេតុថា មិនមានអង្គភាពណាមួយដែលពាក់ព័ន្ធនឹងគោលបំណង ឬ ចង្កោមសកម្មភាព បានរៀបចំសកម្មភាពគាំទ្រដើម្បីអនុវត្តនោះឡើយ ក្នុងនោះ មានចង្កោមសកម្មភាពចំនួន ០២ គឺ ៤២.១ សិក្សានិងរៀបចំក្របខណ្ឌគោលនៃការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម (Performance Based Management-PBM) និង ៤២.២. ពិគ្រោះយោបល់លើគោលការណ៍គ្រប់គ្រងផ្អែកលើសមិទ្ធកម្ម។

យើងអាចសន្និដ្ឋានបានថា គោលបំណងនេះ គឺស្ថិតនៅក្នុងកម្រិតមួយពុំទាន់ឆ្លើយតបបានទាំងស្រុងតាមទិសដៅដែលបានដាក់ចេញនៅឡើយ ដែលទាមទារឱ្យអគ្គនាយកដ្ឋាន ជាពិសេស អគ្គលេខាធិការដ្ឋាន កសហវ ចាំបាច់ត្រូវរៀបចំសកម្មភាពដើម្បីគាំទ្រចង្កោមសកម្មភាព និងគោលបំណងនេះ។

### ៣.៤.៣. គោលបំណង៤៣ ÷ បង្កើតក្របខ័ណ្ឌសវនកម្មផ្អែកលើសមិទ្ធកម្ម

ការបង្កើតក្របខណ្ឌសវនកម្មផ្អែកលើសមិទ្ធកម្ម គឺសំដៅដល់ការត្រួតពិនិត្យឯករាជ្យនៃកម្មវិធី, មុខងារ, ដំណើការ ឬ ការគ្រប់គ្រងប្រព័ន្ធនិងនីតិវិធីរបស់រដ្ឋាភិបាល ដើម្បីវាយតម្លៃថាតើអង្គភាពសម្រេចបាននូវភាពសន្សំសំចៃ, ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន។

ការបង្កើតក្របខណ្ឌសវនកម្មផ្អែកលើសមិទ្ធកម្ម សំដៅលើការបង្កើនការតម្រង់ទិសការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព តាមរយៈការរៀបចំគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មលើសមិទ្ធកម្ម និងការរៀបចំផែនការបណ្តុះបណ្តាលសវនកម្មនៅតាមក្រសួងស្ថាប័ន។ ជាក់ស្តែង គោលបំណងនេះមិនទាន់ដល់ពេលអនុវត្តនិងវាស់វែងបាននៅឡើយទេ ក្នុងនោះ មានចង្កោមសកម្មភាពចំនួន ០២ គឺ ៤៣.១. សិក្សានិងរៀបចំក្របខណ្ឌគោលនៃសវនកម្មផ្អែកលើសមិទ្ធកម្ម (Performance Based Auditing-PBA) និង ៤៣.២. ពិគ្រោះយោបល់លើគោលការណ៍សវនកម្មផ្អែកលើសមិទ្ធកម្ម។

***សំគាល់÷*** *សម្រាប់គោលបំណង **៤២** និង **៤៣** អគ្គនាយកដ្ឋានថវិកាបាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៧-២០២៥ ដែលនឹងបង្កើតក្របខណ្ឌរួមសម្រាប់ដំណាក់កាលទី៣ និងដំណាក់កាលទី៤។*

**៣.៤.៤.គោលបំណង៤៤÷ រៀបចំផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និងអជ្ញាធរសវនកម្មជាតិ) (៧២%)**

ការរៀបចំផែនការកសាងសមត្ថភាព ក្នុងគោលដៅដើម្បីឱ្យអង្គភាពនីតិប្បញ្ញត្តិ និងអជ្ញាធរសវនកម្មជាតិ ពង្រឹងនិងពង្រីកសមត្ថភាពពាក់ព័ន្ធនឹងការងារត្រួតពិនិត្យ និងសវនកម្មផ្អែកលើសមិទ្ធកម្ម។ តាមរយៈការពង្រឹងសមត្ថភាពនេះ នឹងជួយឱ្យការអនុវត្តថវិការបស់រាជរដ្ឋាភិបាលប្រកបដោយភាពសន្សំសំចៃ, តម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ជាក់ស្តែង គោលបំណងនេះសម្រេចបាន ៧២% និងមានចង្កោមសកម្មភាពចំនួន ៦ អនុវត្តដោយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋាន កសហវ ក្នុងនោះ ៤៤.១ រៀបចំផែនការកសាងសមត្ថភាព (Capacity Development Plan-CDP) ៧១%, ៤៤.២ ពិគ្រោះយោបល់និងអនុម័តផែនការកសាងសមត្ថភាព ២០% និង ៤៤.៣ ផ្សព្វផ្សាយនិងអនុវត្តផែនការកសាងសមត្ថភាព (ពុំមានអង្គភាពពាក់ព័ន្ធនឹងការងារនេះរៀបចំសកម្មភាពគាំទ្រទេ)។

<u>**ជាក់ស្តែងសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷**</u>

១. (៤៤.១.១.)សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សរបស់ ក្រសួងស្ថាប័ន លើជំនាញគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេល ៣ ឆ្នាំ (២០១៦-២០១៨) ត្រូវបានរៀបចំ និងដាក់ឱ្យពិគ្រោះយោបល់ **0%**

២. (៤៤.១.២.)ផែនការសកម្មភាព ពង្រឹងសមត្ថភាពរៀបចំគ្រូបង្គោល ស្តីពីការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងស្ថាប័ន ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានរៀបចំ និងដាក់ឱ្យពិគ្រោះយោបល់ **៩៥%**

៣.(៤៤.១.៣.) ចំនួនក្រសួង/ស្ថាប័ន មន្ទីរត្រូវចុះវាយតម្លៃតម្រូវការ នៃវគ្គបណ្តុះបណ្តាល (Traning Need Assessment) ត្រូវបានកំណត់និងរៀបចំ **0%**

៤. (៤៤.១.៤.)ផែនការបណ្តុះបណ្តាលក្របខណ្ឌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់សម្រាប់រយៈពេល ៣ ឆ្នាំ (២០១៦-២០១៨) ត្រូវបានរៀបចំ **៩៨%**

៥. (៤៤.១.៥.)ផែនការត្រួតពិនិត្យ តាមដាន និងវាយតម្លៃតាមបណ្តា ក្រសួង-ស្ថាប័ន មន្ទីរ លើជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់សម្រាប់រយៈពេល ៣ ឆ្នាំ (២០១៦-២០១៨) ត្រូវបានរៀបចំ និងបន្តដាក់ឱ្យពិគ្រោះយោបល់ និងអនុម័ត **៨0%**។

**៣.៥. ផ្នែកទី៥÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព** (៧២%)

ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ត្រូវបានរៀបចំឡើងក្នុងគោលដៅពង្រឹងនិងពង្រីកភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង សមត្ថភាពបច្ចេកទេស ភាពជាម្ចាស់ ការទទួលខុសត្រូវ ឱ្យស្របតាម និងមានសមានគតិភាពជាមួយនឹង ការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងដំណាក់កាលបន្ទាប់។ ទន្ទឹមនេះ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ជាផ្នែកមួយដ៏សំខាន់នៃដំណាក់កាល ទី៣ នេះផងដែរ ដោយផ្តោតសំខាន់ទៅលើ (១) បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ, (២)

បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត និង (៣) ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៦ ផ្នែកទី៥÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព (សម្រេចបាន ៧២%) ដោយមានគោលបំណងចំនួន ៣ និងចង្កោមសកម្មភាពចំនួន ៨ អនុវត្តដោយអគ្គនាយកដ្ឋានចំនួន ១២ រួមមាន÷ អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គលេខាធិការដ្ឋាន, ក្រុមការងារគ្រប់គ្រងគំរោង FMIS, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ, អគ្គាធិការដ្ឋាន, និងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ។ ដើម្បីបង្ហាញ និងស្វែងយល់ពីស្ថានភាពការអនុវត្តការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ដែលអាចសម្រេចបានក្នុងកម្រិតបែបណានោះ របាយការណ៍ត្រីមាសនេះនឹងរំលេចអំពី វឌ្ឍនភាព បញ្ហាប្រឈម និងសំណូមពរទៅតាមគោលបំណងនីមួយៗជាបន្តបន្ទាប់។

**៣.៥.១.គោលបំណង៥១÷ បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់និងការទទួលខុសត្រូវ (៧០%)**

ការបង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់និងការទទួលខុសត្រូវ គឺជាកត្តាសំខាន់ដើម្បីគាំទ្រការងារកែទម្រង់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ភាពជាអ្នកដឹកនាំ សំដៅអ្នកដឹកនាំដែលមានចក្ខុវិស័យវែងឆ្ងាយសម្រាប់តម្រង់ទិស និងអភិវឌ្ឍន៍ស្ថាប័ន, សមត្ថភាពការគ្រប់គ្រង សំដៅសមត្ថភាពក្នុងការរៀបចំផែនការ, ការចាត់ចែង, ការដឹកនាំ និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ ទន្ទឹមនឹងនេះ ការបណ្តុះឆន្ទៈកំណែទម្រង់ គឺធានានូវការចូលរួមការងារកែទម្រង់ឱ្យសកម្ម និងបុរេសកម្ម។

ការបង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់និងការទទួលខុសត្រូវទាមទារនូវការពង្រឹងបន្ថែមទៀត ដើម្បីធានាឱ្យបាននូវការចូលរួមចំណែកក្នុងការកែទម្រង់ប្រកប ដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ៧០% និង មានចង្កោមសកម្មភាពចំនួន ២ អនុវត្តដោយ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានថវិកា, អគ្គលេខាធិការដ្ឋាន កសហវ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, និង អគ្គនាយកដ្ឋានរតនាគាជាតិ គឺ ៥១.១ ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាពគ្រប់គ្រង ៧៨% និង ៥១.២ បង្កើនឆន្ទៈកំណែទម្រង់ភាពជាម្ចាស់ និងការទទួលខុសត្រូវ ៦២%។

**<u>ជាក់ស្តែងសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷</u>**

១. (៥១.១.៣.)សារាចរស្តីពីវិធាននិងនីតិវិធី នៃការបង្កើនសមត្ថភាពជាអ្នកដឹកនាំ និងសមត្ថភាពគ្រប់គ្រងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានរៀបចំ **0%**

២.(៥១.១.៤.)ឯកសារស្តីពីចក្ខុវិស័យគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស កសហវ រយៈពេល ០៣ឆ្នាំ ២០១៧-២០១៩ ត្រូវបានរៀបចំនិងអនុវត្ត **៨៥%**

៣.(៥១.១.៥.)ឯកសារស្តីពីចក្ខុវិស័យពង្រឹងភាពជាអ្នកដឹកនាំ និង សមត្ថភាពគ្រប់គ្រងរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានត្រូវបានសម្រេចនិងអនុវត្ត ៨៥%

៤. កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធនឹងដែនសមត្ថកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរៀបចំចងក្រង និងផ្សព្វផ្សាយ ៥០%។

**៣.៥.២.គោលបំណង៥២÷ បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងវិធានការលើកទឹកចិត្ត (៨០%)**

ការអភិវឌ្ឍន៍ធនធានមនុស្សលើផ្នែកហិរញ្ញវត្ថុសាធារណៈជាមូលដ្ឋាន និងយានសម្រាប់គាំទ្រការងារកែទម្រង់ប្រកបដោយជោជ័យ និងចីរភាព នៃដំណាក់កាលទី៣ និងដំណាក់កាលទី៤។ សុខដុមនីយកម្មការលើកទឹកចិត្តគ្រប់ក្រសួង ស្ថាប័ន គឺធានាដល់ប្រសិទ្ធភាពការអនុវត្តការងារ និងលើកកម្ពស់គណនេយ្យភាពសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការ។

ដើម្បីបង្កើនឆន្ទៈចូលរួម ពីគ្រប់អគ្គនាយកដ្ឋាន និងក្រសួងស្ថាប័ន ការបង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្តជាការចាំបាច់ដែលមិនអាចខ្វះបាន។ ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ៨០% និងមានចង្កោមសកម្មភាពចំនួន ២ អនុវត្តដោយ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានថវិកា និងអគ្គលេខាធិការដ្ឋាន កសហវ ក្នុងនោះ ចង្កោមសកម្មភាព ៥២.១. ពិនិត្យមើលឡើងវិញពីប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៃការបណ្តុះបណ្តាល និងរៀបចំ ផែនការកសាងសមត្ថភាពថ្មី ៧០% និង ៥២.២. ពិនិត្យមើលឡើងវិញពីយន្តការ និងអភិក្រមនៃការផ្តល់ការលើកទឹកចិត្ត រយៈពេលកន្លងមកនិងរៀបចំឱ្យមានយន្តការ និងអភិក្រមថ្មីស្តីពីការផ្តល់ការលើកទឹកចិត្តដែលមានសមធម៌ និងសង្គតិភាព ៩០%។ តាមរយៈវឌ្ឍនភាពក្នុងគោលបំណងនេះមិនមានសូចនាករគន្លឹះណាមួយសម្រេចបានតាមគោលដៅទេ។

<u>**ជាក់ស្តែងសូចនាករមិនសម្រេចបានតាមគោលដៅ គឺ÷**</u>

១. (៥២.១.៣.)គ្រូបង្គោលបន្ថែមចំនួន ៣០នាក់ លើជំនាញថវិកា លទ្ធកម្មសាធារណៈ គណនេយ្យសាធារណៈអធិការកិច្ចហិរញ្ញវត្ថុ សវនកម្ម និងជំនាញពាក់ព័ន្ធ ត្រូវបានជ្រើសរើស ៩០%

២.(៥២.២.១.)ផែនការពិនិត្យសមិទ្ធកម្មនិងស្ថានភាពបំពេញការងាររបស់មន្ត្រី កសហវ ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានសម្រាប់ឆ្នាំ២០១៦ ត្រូវបានអនុវត្ត ៨៥%។

**៣.៥.៣.គោលបំណង៥៣÷ ពង្រឹងការកសាងសមត្ថភាពសម្រាប់ អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ (៦៦%)**

ឈានមកដំណាក់កាលទី៣ ការផ្សាភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការកសាងសមត្ថភាពនៅគ្រប់កម្រិតក្រសួង ស្ថាប័ន ត្រូវបានចាត់ទុកជាកត្តាអាទិភាព ពោលគឺការប្រើប្រាស់ធនធានមនុស្សឱ្យចំណុចជំនាញ និងបណ្តុះបណ្តាលឱ្យចំមន្ត្រីដែលប្រកបដោយសក្តានុពល។ ការកសាងសកមត្ថភាពនេះ សំដៅដំណើរការមួយដែលនាំមកនូវការលើកកម្ពស់ជំនាញ (ទាំងជំនាញទូទៅ និងជំនាញជាក់លាក់) ដែលធ្វើឱ្យប្រសើរឡើងនូវនីតិវិធី និងពង្រឹងស្ថាប័ន។

ការពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងដំណាក់កាលទី៣ ត្រូវបន្តការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីធានាឱ្យបាននូវការចូលរួមចំណែកក្នុងការកែ

ទម្រង់ប្រកបដោយ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ជាក់ស្តែង គោលបំណងនេះជារួមសម្រេចបាន ៦៦% និងមានចង្កោមសកម្មភាពចំនួន ៤ អនុវត្តដោយ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានថវិកា, អគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាល ថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានរតនាគាជាតិ, អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គនាយកដ្ឋាន ឧស្សាហកម្មហិរញ្ញវត្ថុ រួមមាន ៥៣.១.រៀបចំស្ថាប័នដើម្បីឆ្លើយតបនឹងដំណាក់កាលទី៣ រួមមាន(១) ការបញ្ចប់វិភាគមុខងារនៅគ្រប់អគ្គនាយកដ្ឋាន កសហវ និងនាយកដ្ឋាន(២) រៀបចំនិងអនុវត្តផែនការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋាននិងនាយកដ្ឋាននីមួយៗ (៣) រៀបចំនិង ផ្សព្វផ្សាយឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងថ្មី(៤) រៀបចំគោលនយោបាយសម្រាប់យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានវិទ្យា នៅ កសហវ(៥) ការប្រើប្រាស់ជំនួយបច្ចេកទេសប្រកបដោយប្រសិទ្ធភាព និង(៦) កែលម្អការអនុវត្តការងារតាមរយៈការបង្កើតការប្រើប្រាស់បច្ចេកវិទ្យា ៥១%, ៥៣.២. ការអភិវឌ្ឍធនធានមនុស្សសម្រាប់ ដំណាក់កាលទី៣ ដែលរួមមានការបណ្តុះបណ្តាលជំនាញទាំងនៅក្នុងកសហវ និងក្រសួង ស្ថាប័ន ៥៨%, ៥៣.៣. រៀបចំនិងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនង និងសម្របសម្រួលសម្រាប់ដំណាក់កាល ទី៣ (ពុំទាន់មានសកម្មភាពអនុវត្ត), និង៥៣.៤.កំណត់តួនាទី និងការទទួលខុសត្រូវសម្រាប់កែលម្អកិច្ចសម្របសម្រួលរវាងស្ថាប័ន និងអង្គភាព ៩០%។

**<u>ជាក់ស្តែងសូចនាករសម្រេចបានតាមគោលដៅ គឺ៖</u>**

១. សេចក្តីព្រាងផែនការយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស របស់ អគ្គ.ពន្ធដារត្រូវបានបញ្ចប់ត្រឹមកម្រិតក្រុមការងារ និងដាក់ឆ្លងយោបល់ធាតុចូលពីថ្នាក់ដឹកនាំនាយកដ្ឋាន និងអគ្គនាយករង
២. ប្រព័ន្ធគ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យាអគ្គ.ពន្ធដារ ត្រូវបានរៀបចំ
៣. បញ្ជីសារពើភ័ណ្ឌរបស់សាខាពន្ធដារខណ្ឌទាំងអស់នៃ អគ្គ.ពន្ធដារ ត្រូវបានរៀបចំ
៤. ប្រព័ន្ធគ្រប់គ្រងឯកសារលិខិតគតិយុត្តិ (e-Doc) ត្រូវបានបានឱ្យប្រើប្រាស់ជាផ្លូវការតាមនាយកដ្ឋាននីមួយៗ និង លេខាធិការដ្ឋានក្នុងអគ្គ.រតនាគារជាតិ
៥. ក្របខណ្ឌមុខងារអគ្គាធិការដ្ឋាន ១០ក្រសួង ត្រូវបានសិក្សាលើបទបញ្ញត្តិជាធរមាន
៦. វគ្គបណ្តុះបណ្តាលចំនួន ១២ វគ្គ ដែលមានមន្ត្រីរាជការចំនួន ១៣២៩ រូបទទួលបានការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពក្នុងការអនុវត្តការងារប្រចាំថ្ងៃ
៧. វប្បធម៌បង់ពន្ធនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលប្រចាំឆ្នាំ ២០១៤-២០១៨ ត្រូវបានបណ្តុះបណ្តាលដល់មន្ត្រីនិងអ្នកជាប់ពន្ធតាមខណ្ឌ-ក្រុង-ស្រុកចំនួន ៥០។

**<u>រីឯសូចនាករមិនសម្រេចបានតាមគោលដៅ គឺ៖</u>**

១. (៥៣.១.៥.)ប្រព័ន្ធបច្ចេកវិទ្យាដើម្បីគ្រប់គ្រងទិន្នន័យទ្រព្យសម្បត្តិរដ្ឋនិងបញ្ជីសារពើភណ្ឌ របស់គ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបង្កើត ០%

២. (៥៣.១.១០.)សេចក្តីព្រាងសារាចរស្តីពីការពិពណ៌នាលក្ខណៈសម្បត្តិរបស់មន្ត្រីរាជការ កសហវ ត្រូវបានពិគ្រោះយោបល់ **៧០%**

៣.(៥៣.១.១២.)ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ កសហវ តាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានរៀបចំ **៧០%**

៤. (៥៣.១.១៣.)សេចក្តីព្រាងទី១ ឯកសារគោលនយោបាយបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ សម្រាប់ កសហវ ត្រូវបានរៀបចំបញ្ចប់ **៣៥%**

៥. (៥៣.១.១៤.)ក្របខ័ណ្ឌគតិយុត្តគ្រប់គ្រងនិងសម្របសម្រួលលើការប្រើប្រាស់ ICT នៅក្នុង កសហវ ត្រូវបានផ្សព្វផ្សាយជូនគ្រប់អង្គភាពក្រោមឱវាទ កសហវ និងដាក់ឱ្យអនុវត្ត **៨៥%**

៦. (៥៣.១.១៥.)ផែនការរយៈពេលមធ្យម (២០១៧-២០១៩) លើការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ សម្រាប់ កសហវ ត្រូវបានរៀបចំ **២៥%**

៧. (៥៣.២.៦.)គ្រូបង្គោលសម្រាប់ការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរួច **0%**។

ដោយឡែក សកម្មភាព ៥៣.២.១. រៀបចំបណ្តុះបណ្តាលគ្រូបង្គោលអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវលើកទៅធ្វើនៅត្រីមាសទី៣ វិញ, សកម្មភាព ៥១.១.២.រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្ស កសហវ រយៈពេល០៣ឆ្នាំ ២០១៧-២០១៩ ស្នើសុំពន្យាពេលទៅត្រីមាសបន្ទាប់, និងសកម្មភាព ៥៣.២.២.រៀបចំវគ្គបណ្តុះបណ្តាលខ្លីលើការប្រើប្រាស់កម្មវិធីគណនេយ្យ ( Qick Book, Peachtree) ស្នើសុំលើកទៅអនុវត្តនៅត្រីមាសទី៣។

## ៤. បញ្ហាប្រឈម

- ការរៀបចំផែនការសកម្មភាព និងគុណភាពនៃសូចនាករ ពុំទាន់គ្រប់ជ្រុងជ្រោយ និងឆ្លើយតបទៅនឹងមុខងារ និងភារកិច្ច និងលទ្ធផលរំពឹងទុកនៅឡើយ ដែលនាំឱ្យអង្គភាពនីមួយៗ មានការលំបាកក្នុងការវាស់វែងសមិទ្ធកម្មរបស់សាមីអង្គភាព
- អង្គភាពក្រោមឱវាទ កសហវ មួយចំនួននៅតែបន្តលើហេតុថា មានការងារផ្សេងៗ ឬ ប្រចាំថ្ងៃច្រើន ឬ ការងារមិនបានគ្រោងទុកកើតមានឡើងសម្រាប់អនុវត្ត ដែលនាំឱ្យមានការយឺតឬមិនអនុវត្តសកម្មភាពនិងសូចនាករដែលបានឯកភាពដាក់ចេញនៅក្នុង GDAP3
- ការចូលរួមគាំទ្រនិងអនុវត្តសារាចររាជរដ្ឋាភិបាលលេខ ០៩ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ អនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមិនទាន់បានពេញលេញ និងគ្រប់ជ្រុងជ្រោយនៅឡើយ ពោលគឺមានកម្រិតទាប
- ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងបន្ទាត់គណនេយ្យភាព គឺជាបុរេលក្ខណៈសម្បត្តិខ្វះមិនបានដើម្បីសម្រេចចក្ខុវិស័យកែទម្រង់ ក៏មិនតែនៅមិនទាន់គ្រប់ជ្រុងជ្រោយ និងនៅមានកម្រិត

- ទស្សនៈនិងការយល់ឃើញរយៈពេលមធ្យម និងវែងសម្រាប់ការងារកែទម្រង់ជារួមនៅមិនទាន់អាចទទួលយកបាន រវាង **អ.គ.ហ.** និងអង្គភាពនៃកសហវ និងក្រសួង ស្ថាប័ន ដែលអាចក្លាយជាឧបសគ្គដល់ការសម្រេចគោលដៅតែមួយ
- មិនទាន់បានរៀបចំបញ្ចប់ទស្សនស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ដំណាក់កាលទី៣
- គម្រោង FMIS ដំណាក់កាលទី១ នៅទាន់បានរៀបចំបញ្ចប់ឱ្យបានគ្រប់ជ្រុងជ្រោយ ដោយហេតុថា នៅតែមានបញ្ហាប្រឈមមួយចំនួននៅតែកើតមានសម្រាប់ អង្គភាពពាក់ព័ន្ធ ក្រោមឱវាទ កសហវ ដែលជាឧបសគ្គក្នុងការសម្រេចបានដំណាក់កាលទី១ និងឈានទៅអនុវត្តផែនការដំណាក់កាលទី២៕

## ៥. សំណូមពរ

- អគ្គនាយកដ្ឋាន/អង្គភាព កសហវ គួរពិនិត្យមើលឡើងវិញពីសូចនាករដែលបានកំណត់រួច និងសូចនាករដែលដៃគូអភិវឌ្ឍន៍បានស្នើ ជាពិសេស សូចនាករដែលស្ថិតក្នុងឬពាក់ព័ន្ធនឹងដែនសមត្ថកិច្ចរបស់អង្គភាព ដើម្បីត្រៀមរៀបចំផែនការសកម្មភាពអនុវត្ត ២០១៧
- ស្នើក្រុមការងារគ្រប់គ្រងគម្រោង FMIS ពិនិត្យ និងមានរបាយការណ៍ជាក់លាក់ស្តីពីបិទបញ្ចប់គម្រោង FMIS ដំណាក់កាលទី១ និងដោះស្រាយបញ្ហាដែលនៅសល់ឱ្យបានស្រេច ដើម្បីឱ្យ អគហ. មានលទ្ធផលក្នុងការចូលរួមគាំទ្រការអនុវត្តគម្រោងបន្ត
- ស្នើ ពិនិត្យពិភាក្សា និងសម្រេច ក្នុងការប្រគល់ឱ្យអង្គភាពដែលពាក់ព័ន្ធនឹងមុខងារ និងភារកិច្ចនៃគោលបំណងទី **៤២.** បង្កើតក្របខណ្ឌគណនេយ្យភាពនៃសមិទ្ធកម្ម និង **៤៣.** បង្កើតក្របខណ្ឌសវនកម្មផ្អែកលើសមិទ្ធកម្ម ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តនៅត្រីមាសទី៤ ឆ្នាំ២០១៦
- ស្នើសុំការសម្រេចពីគណៈកម្មការ លើការផ្តល់ពិន្ទុសូន្យ ចំពោះការយឺតយ៉ាវនៃការផ្តល់របាយការណ៍ប្រចាំត្រីមាស (២ សប្តាហ៍) ដោយអនុលោមតាមសារាចរ ០៩
- ស្នើអង្គភាពស្នូលដែលពាក់ព័ន្ធក្នុងគម្រោង FMIS ពិនិត្យ និងរៀបចំជារបាយការណ៍ជាក់លាក់ ដោយរំលេចនូវវឌ្ឍនភាព និងបញ្ហាប្រឈមដែលនៅសល់ក្នុងដំណាក់កាលទី១ នៃគម្រោង FMIS
- ស្នើវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពន្លឿនការរៀបចំយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍន៍សមត្ថភាព ឬ ការបណ្តុះបណ្តាលការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- ស្នើពន្លឿនការរៀបចំផែនយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាកម្ពុជាឆ្នាំ២០១៧-២០២៥
- ពន្លឿនការរៀបចំក្របខណ្ឌចំណាយរយៈពេលមធ្យម ដែលអូសបន្លាយរយៈពេលយូរមកហើយ
- ស្នើពន្លឿនការរៀបចំលិខិតបដ្ឋានគតិយុត្តិពាក់ព័ន្ធលទ្ធកម្មសាធារណៈ (វឌ្ឍនភាពមានតិចតួច)
- ស្នើពន្លឿនការរៀបចំគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ

- ស្នើសុំការពិនិត្យនិងសម្រេច ដើម្បីឱ្យមានការចូលរួមពីមន្ត្រី ឬថ្នាក់ដឹកនាំនៃបណ្ដាអង្គភាពពាក់ព័ន្ធ គសហវ នៅពេលមានកម្មវិធីផ្សព្វផ្សាយការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅរួមគ្នាកំណត់បញ្ហាឱ្យបានជាក់មុននឹងឈានទៅដាក់ចេញនូវដំណោះស្រាយ៕

## ៦. សន្និដ្ឋាន

របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី២ ឆ្នាំ២០១៦ ទោះបីមានវឌ្ឍនភាពស្របទៅតាមសូចនាករដែលបានកំណត់ក៏ដោយ ក៏នៅមានសូចនាករមួយចំនួនទៀតនៅមិនទាន់សម្រេចបានតាមគោលដៅនៅឡើយ ដោយសារកត្តាអត្តនោម័ត/ សត្យានុម័ត។ របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី២ នេះ ក៏បានរំលេចឱ្យឃើញពីភាពចាំបាច់ក្នុងការពិនិត្យមើលឡើងវិញ និងកែសម្រួលសូចនាករ/ សកម្មភាពលម្អិតមួយចំនួន នៅត្រីមាស និងឆ្នាំបន្ទាប់ ដើម្បីសម្រេចបានតាមគោលដៅរួមនៃ CAP3។

ជាក់ស្ដែង ការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ ត្រីមាសទី២ នេះ ក៏មិនមានភាពខុសប្លែកជាងការអនុវត្តត្រីមាសទី១ ដែរ ដោយឡែក របាយការណ៍នេះ គួរកត់សម្គាល់ផងដែរនូវសមិទ្ធផលជារួមទៅតាមផ្នែកនីមួយៗដែលបានចូលរួមអនុវត្តដោយអង្គភាពក្រោម ឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈការដាក់ចេញនូវផែនការសកម្មភាពលម្អិតដើម្បីគាំទ្រ ដល់ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសគឺដំណាក់កាលទី៣នេះតែម្តង។ យោងតាមរបាយការណ៍នេះ យើងអាចសន្និដ្ឋានជារួមបានថា÷

**១.បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា÷** ផ្អែកលើសូចនាករសមិទ្ធកម្មគន្លឹះទាំង ៥ ឃើញថាគម្លាតចំណូល និងចំណាយថវិកាជាតិកាន់តែតូចធៀបនឹងច្បាប់ថវិកា ដែលបានអនុម័ត, លំហូរចំណូលនិងចំណាយថវិកាកាន់តែរលូន, ការទូទាត់សាច់ប្រាក់កាន់តែមានភាពល្អប្រសើរ ព្រមទាំងកាត់បន្ថយបានទាំងស្រុងនូវបញ្ហាបំណុលកកស្ទះ។ ផ្អែកតាម លទ្ធផលនៃចង្កោមសកម្មភាព ផ្នែកនេះសម្រេចបាន ៨០% មានន័យថា ការងារពង្រឹង ផ្នែកភាពជឿទុកចិត្តបាននៃថវិកា បាននិងកំពុងបន្តអនុវត្តបានប្រសើរផងដែរ។ ជាទូទៅ ភាពជឿទុកចិត្តបាននៃថវិកា អាចរក្សាបានជាសារវន្ត ប៉ុន្តែចាំបាច់ត្រូវបន្តពង្រឹងកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធ ជាពិសេស ប្រសិទ្ធភាពនៃកិច្ចដំណើរការរៀបចំ និងការអនុវត្តផែនការចំណូល និងចំណាយក្នុងឆ្នាំ គឺពុំទាន់មានភាពសុក្រឹត និងសមត្ថភាពព្យាករណ៍ (ក្នុងឆ្នាំ) ហាក់នៅមានកម្រិត។ ទន្ទឹមនេះ ការគ្រប់គ្រងសាច់ប្រាក់ក៏ទាមទារឱ្យមានការពង្រឹងបន្ថែម ជាពិសេសលើប្រព័ន្ធ និងក្របខណ្ឌគតិយុត្តផ្សេងៗដែលជាមូលដ្ឋានក្នុងការគាំទ្រការងារនេះ។ ភាពជឿទុកចិត្តបាននៃថវិកានៅតែអាចធានាបាន ប៉ុន្តែនៅមិនទាន់មានស្ថិរភាពនៅឡើយ។

**២.បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ÷** ជារួមផ្អែកតាមលទ្ធផលចង្កោមសកម្មភាពដែលសម្រេចបាន ៨២% យើងអាចសន្និដ្ឋានបានថា កិច្ចការសំខាន់ៗ និងចាំបាច់មួយចំនួន ជាពិសេស សមាសធាតុចាំបាច់អាចយកមកប្រើប្រាស់បាន សម្រាប់ធានាដល់ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារនៈ (FMIS) បានទាន់ពេលវេលាតាមកាលកំណត់។ ទោះជាយ៉ាងនេះក្តី ការងារដែលគួរតែបន្ថែមការយកចិត្តទុកដាក់ខ្ពស់នោះ គឺភាពច្បាស់លាស់នៃការបិទបញ្ចប់គម្រោង FMIS

ដំណាក់កាលទី១ តែម្តង ទន្ទឹមនឹងការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព ជាពិសេស ចំពោះក្រសួងស្ថាប័ន ដែលបានអនុវត្តថវិកាកម្មវិធីពេញលេញ និងក្រសួងស្ថាប័នដែលនឹងអនុវត្តថវិកាកម្មវិធី ពុំទាន់ត្រូវបានរៀបចំជាសកម្មភាពឱ្យបានជាក់លាក់។ ផ្នែកនេះ នៅតែធានាបាន ប៉ុន្តែអាចនឹងជួបប្រទះកិច្ចប្រឈមនាពេលខាងមុខ ប្រសិនការបញ្ចប់ការងារ FMIS ដំណាក់កាលទី១ មិនទាន់ពេលវេលា និងកង្វះការចូលរួមរៀបចំ និងឆន្ទៈសម្រាប់ផែនការដំណាក់កាលទី២។

**៣. ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ÷** សម្រាប់ការងារនេះ ជារួមផ្អែកតាមលទ្ធផលចង្កោមសកម្មភាពដែលសម្រេចបាន ៨៧% ដោយហេតុថា ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ គឺជាដំណាក់កាលដ៏សំខាន់នឹងចាំបាច់ដែលមិនអាចមើលរំលងបាននូវរាល់ការរៀបចំសកម្មភាពលម្អិតគាំទ្រពីគ្រប់អង្គភាព កសហវ និងក្រសួងស្ថាប័ន។ ជាក់ស្តែង គឺការដែលចាំបាច់ចំពោះមុខ និងមិនអាចខ្វះបាននោះ គឺការពង្រឹងការរៀបចំ និងកំណត់នូវសិទ្ធអំណាច និងមុខងារភារកិច្ចសម្រាប់អង្គភាពថវិកានៅតាមក្រសួងស្ថាប័ន អនុវត្តថវិកាកម្មវិធី និងត្រៀមអនុវត្ត។ ទន្ទឹមនេះ ការពង្រឹងការរៀបចំផែនការថវិកា (ចំណូលចំណាយ) រយៈពេលមធ្យម និងផែនការយុទ្ធសាស្ត្រថវិកា និងក្របខណ្ឌគតិយុត្តផ្សេងៗ ដែលគាំទ្រដល់កិច្ចដំណើរការការងារទាំងអស់នេះ ការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិនិងការរៀបចំគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រយៈពេលមធ្យម និងវែង និងការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាតាមកម្មវិធីគួរត្រូវបានយកចិត្តទុកដាក់ និងពង្រឹងសកម្មភាពអនុវត្ត។ ផ្នែកនេះ កាន់តែសំខាន់ ដែលការងារចាំបាច់ត្រូវពន្លឿនការរៀបចំ និងអនុវត្ត ដូចជា ការរៀបចំផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៧-២០២៥, ការរៀបចំ MTEF និងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ។

**៤. ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់÷** សម្រាប់ផ្នែកនេះ ជារួម ផ្អែកតាមលទ្ធផលចង្កោមសកម្មភាពផ្នែកនេះសម្រេចបាន ៧៩% ដោយហេតុថា ផ្នែកនេះសម្រេចបានទាប នោះបញ្ជាក់អំពីភាពចាំបាច់ក្នុងការបន្ត និងពង្រឹងការគាំទ្រដល់ផ្នែកនេះ បន្ថែមទៀតនោះ គឺ ក្របខ័ណ្ឌថវិកា ក្របខ័ណ្ឌគណនេយ្យភាព និងក្របខ័ណ្ឌសវនកម្មដោយផ្អែកលើសមិទ្ធកម្មដែលផ្សារភ្ជាប់ការចំណាយសម្រាប់កម្មវិធីនីមួយ។ ទន្ទឹមនេះ អង្គភាព កសហវ និងក្រសួងស្ថាប័ន គួរពិនិត្យ និងរៀបចំសកម្មភាពលម្អិតគាំទ្ររួមមាន (១) បង្កើតក្របខ័ណ្ឌថវិកាដោយផ្អែកលើសមិទ្ធកម្ម (២) បង្កើតក្របខណ្ឌគណនេយ្យភាពនៃសមិទ្ធិកម្ម (៣) បង្កើតក្របខណ្ឌសវនកម្មលើសមិទ្ធិកម្ម និង (៤) រៀបចំផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និងអជ្ញាធរសវនកម្មជាតិ)។ ផ្នែកនេះ មានសកម្មភាពលម្អិតគាំមិនទាន់ពេញលេញ ដែលចាំបាច់ឱ្យមានការរៀបចំ និងកំណត់ការទទួលខុសត្រូវច្បាស់លាស់។

**៥. ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព÷** សម្រាប់ផ្នែកនេះ ជារួមផ្អែកតាមលទ្ធផលចង្កោមសកម្មភាពផ្នែកនេះសម្រេចបាន ៧២% ដោយហេតុថា ផ្នែកនេះសម្រេចបាន

ទាបជាង បណ្ដាផ្នែកទាំង ៤ផ្សេងទៀត នោះបញ្ជាក់អំពីភាពចាំបាច់ក្នុងការបន្ត និងពង្រឹងការគាំទ្រដល់ផ្នែកនេះ បន្ថែមទៀតនោះ គឺ យុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស ផែនការផ្សព្វផ្សាយ និងការបណ្ដុះបណ្ដាលពីសកម្មភាពកែទម្រង់ ឱ្យបានទូលាយ, ការរៀបចំឱ្យប្រសើរជាងមុន និងធ្វើបច្ចុប្បន្នកម្មនូវឯកសារបណ្ដុះបណ្ដាលវិស័យជំនាញ។ ពង្រឹងនិងពង្រីកភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រងសមត្ថភាពបច្ចេកទេស ភាពជាម្ចាស់ ការទទួលខុសត្រូវ និងមានសមានគតិភាពជាមួយនឹង ការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ និងដំណាក់កាលបន្ទាប់។ អគ្គនាយកដ្ឋានមួយចំនួនមិនបានរៀបចំសកម្មភាពគាំទ្រផ្នែកនេះ និងទាមទារឱ្យមានការសហការជាមួយកំណែទម្រង់រដ្ឋបាលសាធារណៈ៕

## ឧបសម្ព័ន្ធ៖ តារាងរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០១៦